# ជីវិតឆ្លួងស្លើយ

ភាក់ទង



LIBRARY

៣២៥.
៤១

...ផ្ញើទៅគ្រួសារ សង្គម ស្នេហា
ពាណិជ្ជកម្ម និង លិខិតផ្សេងៗ

www.budinst.gov.kh www.elibraryofcambodia.org

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីហ្សូ កូស៊ី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh        www.elibraryofcambodia.org




www.elibraryofcambodia.org

៣២៥.៤១

# មាតិកា

ទំព័រ


## I- លិខិតស្នេហា ឬការទាក់ទងរវាងបុរស-ស្ត្រី

១- លិខិតបុរសសំដែងស្នេហាចំពោះនារីម្នាក់ធ្លាប់ស្គាល់គ្នា ---------- ១

២- លិខិតបន្ថែមលិខិតខាងលើ ពេលមិនឃើញតបវិញ ---------- ៦

៣- លិខិតឆ្លើយតបនឹងលិខិតទាំងពីរខាងលើ ---------- ៧

៤- លិខិតផ្ញើទៅសង្សារក្រោយពេលស្តីដណ្តឹងរួច ---------- ៩

៥- លិខិតផ្ញើទៅគូដណ្តឹងពេលឃ្លាតទៅឆ្ងាយ ---------- ១១

៦- លិខិតតបនឹងលិខិតខាងលើ ---------- ១២

៧- លិខិតផ្ញើទៅមិត្តនារីម្នាក់ ---------- ១៣

៨- លិខិតផ្ញើទៅគូកំណាន់ចិត្ត ---------- ១៥

៩- លិខិតគូកំណាន់ចិត្តឆ្លើយតបនឹងលិខិតខាងលើ ---------- ១៧

១០- លិខិតផ្ញើទៅគូសង្សារ ---------- ១៨

១១- លិខិតតបនឹងលិខិតខាងលើ ---------- ២០

១២- លិខិតសុំទោសគូកំណាន់ចិត្ត ---------- ២៣

១៣- លិខិតបដិសេធនិងពាក្យសុំរៀបការ ---------- ២៥

១៤- លិខិតលាយកំហឹង បុរសម្នាក់ផ្ញើទៅមិត្តនារី ---------- ២៦

១៥- លិខិតឆ្លើយតបលិខិតខាងលើ ---------- ២៩

១៦- លិខិតសារភាពពីកំហុសខ្លួនចំពោះមិត្តនារី ---------- ៣១

១៧- លិខិតជាចំណងដៃ ក្នុងពេលរៀបភាពាហ៍ពិពាហ៍របស់អតីតសង្សារ ៣៣

## II- លិខិតសំរាប់កិច្ចការផ្សេងៗ

១- លិខិតអញ្ជើញ

ក- លិខិតអញ្ជើញមិត្តចូលរួមដំណើរទេសចរណ៍ ---------- ៣៥

ខ- លិខិតអញ្ជើញចូលរួមពិធីសម្ពោធ ---------- ៣៦


LIBRARY BUDDHIST INSTITUTE

www.budinst.gov.kh www.elibraryofcambodia.org

គ- លិខិតអញ្ជើញមិត្តឱ្យមកជួប -------------------- ៣៧
ឃ- លិខិតអញ្ជើញមិត្ត មកលេងទីក្រុង ---------------- ៣៨
២- លិខិតយល់ព្រម ------------------------------ ៣៩
៣- លិខិតបដិសេធ
ក- លិខិតបដិសេធមិនបានរួមដំណើរទេសចរណ៍ ---------- ៤០
ខ- លិខិតប្រកែកមិនទៅជួប ----------------------- ៤១
៤- លិខិតសូមអភ័យទោស ------------------------- ៤១
៥- លិខិតសុំជួលបន្ទប់សំណាក់ណាមួយ ----------------- ៤៣
៦- លិខិតសុំធ្វើការក្នុងគ្រឹះស្ថានជំនួញណាមួយ ------------- ៤៤
៧- លិខិតឆ្លើយតបនឹងលិខិតខាងលើ ------------------ ៤៥
៨- លិខិតបៅជាងមកជួសជុលផ្ទះ --------------------- ៤៦
III-លិខិតជូនពរនិងសំដែងទឹកចិត្ត
១-លិខិតជូនពរ
ក- ជូនពរមិត្ត ក្នុងឱកាសឡើងឋានៈថ្មី ---------------- ៤៧
ខ- លិខិតជូនពរថ្ងៃបុណ្យណូអែល ------------------- ៤៨
គ- សិស្សជូនពរដល់គ្រូក្នុងឱកាសចូលឆ្នាំថ្មី -------------- ៤៩
ឃ- លិខិតជូនពរគូកំណាន់ចិត្តក្នុងថ្ងៃចូលឆ្នាំថ្មី ------------ ៤៩
ង- លិខិតផ្ញើជូនពរមិត្តក្នុងពេលរៀបអាពាហ៍ពិពាហ៍ ------- ៥០
២- លិខិតសំដែងទឹកចិត្ត
ក- លិខិតសម្តែងសេចក្តីរីករាយចំពោះមិត្តដែលទើបបានបុត្រ ---- ៥១
ខ- លិខិតសំដែងសេចក្តីរីករាយចំពោះបុត្រមិត្រ ទើបប្រឡងជាប់ - ៥១
គ- លិខិតសិស្សថ្លែងអំណរគុណគ្រូក្រោយពេលប្រឡងជាប់ ------៥២
IV-លិខិតសំរាប់គ្រួសារ
១- លិខិតសិស្សម្នាក់ផ្ញើទៅឪពុកម្តាយ ------------------ ៥៥

www.budinst.gov.kh www.elibraryofcambodia.org

២- លិខិតឆ្លើតបពីឪពុកម្ដាយទៅកូនវិញ ------------------ ៥៦

៣- លិខិតរបស់កូនផ្ញើទៅម្ដាយ ------------------ ៥៧

៤- លិខិតរបស់ម្ដាយផ្ញើទៅកូន ------------------ ៥៩

៥- លិខិតក្មួយស្រីផ្ញើទៅឪពុកធំ-ម្ដាយធំ ------------------ ៦០

## V- លិខិតពាណិជ្ជកម្ម ឬ កិច្ចការជំនួញ

១- លិខិតជូនដំណើងពីក្រុមហ៊ុនលក់រថយន្ត ------------------ ៦២

២- លិខិតសួរថ្លៃ និងសុំគំរូ ------------------ ៦៣

៣- លិខិតតបនឹងលិខិតសួរថ្លៃនិងគំរូខាងលើ ------------------ ៦៤

៤- លិខិតបញ្ជាទិញទំនិញ ------------------ ៦៥

៥- លិខិតប្រគល់ទំនិញ ------------------ ៦៦

៦- លិខិតផ្ញើទៅសុំខ្ចីប្រាក់ ------------------ ៦៦

៧- លិខិតថ្លែងអំណរគុណដល់មិត្រដែលឱ្យខ្ចីប្រាក់ ------------------ ៦៧

៨- លិខិតផ្ញើទៅទារបំណុល ------------------ ៦៨

៩- លិខិតសុំអភ័យទោសអំពីម្ចាស់បំណុល ------------------ ៦៩

## VI- លិខិតផ្ទុកការ និងដាក់ជូនទីចាត់ការ

១- លិខិតឧទ្ទេសនាម ------------------ ៧០

២- លិខិតសុំអនុញ្ញាតរៀបអាពាហ៍ពិពាហ៍ ------------------ ៧១

៣- លិខិតផ្ញើទៅសាលារៀន ------------------ ៧២

៤- លិខិតសុំអនុញ្ញាតសង់រោងធ្វើបុណ្យ ------------------ ៧៥

៥- លិខិតផ្ញើទៅវិជ្ជបណ្ឌិត ------------------ ៧៦

៦- លិខិតសុំបង់ប៉ាតង់ ------------------ ៧៧

## VII- លិខិតកិច្ចសន្យាជួលឬលក់វត្ថុនានា

១- កិច្ចសន្យាជួលផ្ទះ ------------------ ៧៨

២- កិច្ចសន្យាសាងសង់ ------------------ ៨០


www.budinst.gov.kh www.elibraryofcambodia.org

# I-លិខិតស្នេហា ឬ ការទាក់ទងរវាងបុរស-ស្ត្រី

លិខិតនេះ ជាលិខិតមួយដែលយើងត្រូវសរសេរឱ្យបានផ្អែមល្ហែមលើសលិខិតអ្វីៗ ទាំងអស់ ។ អ្នកសរសេរតែងព្យាយាមសរសេរឱ្យបានវែងសេចក្តីច្រើន ដើម្បីឱ្យបានរៀងច្រើន ដ្បិតជាលិខិតថ្លែងនូវមនោសញ្ចេតនាដែលផុះចេញពីដួងចិត្តពិតៗ ។

ដូច្នេះរបៀបសរសេរលិខិតនេះមិនជាពិបាកអ្វីទេ ឱ្យតែនឹកឃើញពាក្យល្អសំខាន់សំរាប់ខ្លួនគេ គេអាចដាក់បានទាំងអស់ ប៉ុន្តែគ្រាន់តែបេះឆ្នៃពាក្យឱ្យទន់ភ្លន់ផ្អែមល្ហែម ដើម្បីកុំឱ្យអ្នកទទួលសំបុត្រនោះដកចិត្តឬដាច់ចិត្តធ្វើព្រងើយបាន ។

## ១-លិខិតសុភាពបុរសម្នាក់សម្តែងស្នេហាដ៏បរិសុទ្ធចំពោះនារីម្នាក់ដែលធ្លាប់ស្គាល់គ្នា

ក្រោមពន្លឺដួងចន្ទ្រាពេញវង់ពេញបូរមីថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ១៩៩៩

ផ្ទះលេខ ១៧OB ផ្លូវលេខ ១៦៧. ចំការមន

មកដល់អូន **លក្ខិណា** កំពូលដួងចិត្តបង

នេះគួរចាត់ទុកជាមហាព្រឹត្តិការណ៍មួយសំរាប់ជីវិតបង ហើយនេះក៏ជាលើកដំបូងដែរ ដែលបងបានលើកប៉ាកាសរសេរសំបុត្រ ។ ការដែលបងសរសេរសំបុត្រនេះ បងហាក់ដូចជាគ្មានដឹងខ្លួនថាបងចង់សរសេរយ៉ាងណាសោះទេ ដ្បិតពាក្យពេចន៍ទាំងនេះ សុទ្ធតែផុសចេញមកពីដួងចិត្តដ៏បរិសុទ្ធរបស់បងដ៏ពិតៗ ។ ដូច្នេះបងសូមអភ័យទោសអូនជាមុន បើសិនជាពាក្យបង

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

ទាំងនោះមិនគាប់អធ្យាស្រ័យអូនទេ សូមអូនមេត្តាអនុគ្រោះអធ្យាស្រ័យឱ្យបងផង ព្រោះពាក្យពេចន៍ទាំងនេះ សុទ្ធតែផុសចេញពីបេះដូងបរិសុទ្ធរបស់បងយ៉ាងពិតៗ ។

លក្ខិណា ! តើអូនដឹងទេ ! អស់រយៈពេលជាយូរខែឆ្នាំមកហើយ គឺតាំងពីបងបានជួបនឹងអូននានាទីដំបូងមកម្ល៉េះ ដែលបងបានលួចស្រឡាញ់អូន បងបានធ្លាក់ទៅក្នុងអន្លង់មន្តស្នេហ៍អូនដ៏សែនជ្រៅ បងតែងលួចមើលនូវកិរិយាដ៏ទន់ភ្លន់ វាចាដ៏ទន់ភ្លន់ ដួងនេត្រាយ៉ាងស្រទន់មុតថ្លា ស្នាមញញឹមដ៏សែនស្រស់ប្រៀបដូចជាគ្រាប់ពេជ្រមួយគ្រាប់ដែលកំពុងបញ្ចេញពន្លឺរស្មីចិញ្ចែងចិញ្ចាចនិងមានតំលៃមិនអាចកាត់ថ្លៃបាននៅក្នុងដួងចិត្តបង ។ ពីមួយវិនាទីទៅមួយវិនាទីចិត្តស្រឡាញ់ដែលផុសចេញពីដួងចិត្តដ៏បរិសុទ្ធរបស់បងចំពោះអូនកាន់តែខ្លាំងទៅៗ រហូតដល់ធ្វើឱ្យបងទន្ទេញតែឈ្មោះអូននៅជាប់ក្នុងបេះដូងបងជានិច្ច ហើយបងតែងនិយាយប្រាប់ខ្លួនឯងថា ជាតិនេះ បងស្រឡាញ់តែអូនម្នាក់ បងស្មោះតែអូនម្នាក់ ទោះបីមហាសមុទ្ររីងក្លាយទៅជាថ្ម មេឃរលំភ្នំរលាយជាទឹក ក៏បងនៅតែស្រឡាញ់អូនៗ បងប្រាថ្នាជួបអូនគ្រប់ៗជាតិ ។ លក្ខិណា ! ពៅព្រលឹងមាសបង បើគ្មានរូបអូន ក៏គ្មានរូបបងដែរ បងមិនអាចរស់នៅដោយគ្មានអូនបានទេ ប្រៀបដូចជារាត្រីមិនអាចគ្មានដួងព្រះចន្ទ្រាបានអញ្ចឹងដែរ ។ ជាតិនេះបើបងបានអូនមកធ្វើគូគៀកកើយបីបមថ្នាក់ថ្នម តាមសេចក្ដីប្រាថ្នាមែននោះ បងគិតថា បងជាបុរសម្នាក់ដែលមានវាសនាជាងគេនៅលើលោកនេះ ជាបុរសបានរស់នៅលើគំនរនៃសុភមង្គល ពោរពេញទៅដោយសុភមង្គលនៅក្នុងជីវិត ។ ហ៊ឺ ! លក្ខិណាកំពូងជីវិតបងអើយ ! បង

www.budinst.gov.kh www.elibraryofcambodia.org

ស្រឡាញ់អូនស្មើរលេបទៅហើយ បើបងអាចលេបអូនបាន បងនឹងលេបអូនទុកសំរាប់តែបងម្នាក់ និងដើម្បីអោយផុតពីក្រសែចក្ខុរបស់បុរសទាំងឡាយក្នុងលោកនេះ ។ អូនដឹងទេថា អូនគឺជាឱសថទិព្វ ដែលអាចធ្វើអោយបងមានកម្លាំងចិត្ត ប្រឹងព្យាយាមតស៊ូនឹងជីវិត ហ៊ានពុះពារគ្រប់ឧបសគ្គទាំងអស់ និងធ្វើអោយបងហ៊ានលះបង់អ្វីៗ ទាំងអស់ សូម្បីជីវិតរបស់បងដើម្បីអូនតែម្នាក់។ ទំហំនៃសេចក្តីស្រឡាញ់របស់បងចំពោះអូនមានទំហំធំជាងអ្វីទាំងអស់នៅលើលោកនេះរហូតដល់មិនអាចវាស់បាន មានជម្រៅជាងអ្វីៗទាំងអស់សូម្បីមហាសមុទ្រប៉ាស៊ីហ្វិចក៏មិនអាចមានជម្រៅជ្រៅជាងសេចក្តីស្រឡាញ់របស់បងចំពោះអូនបានដែរ មានកំពស់ខ្ពស់ជាងភ្នំព្រះសុមេរុ មានឱជារសផ្អែមល្ហែមជាងទឹកឃ្មុំ មានសម្ផស្សល្អជាងផ្កាកូលាបទៅទៀត ហើយបងប្រគល់ស្នេហ៍ទាំងអស់នោះជូនអូនដោយសុទ្ធចិត្ត គ្រប់ដង្ហើមចេញចូលរបស់បង គ្រប់ជំហានទៅមករបស់បង គ្រប់វិនាទីនៃទិវារាត្រី បងតែងនឹកមមៃទៅដល់អូនជានិច្ច ។ រូបអូនឋិតក្នុងសតិអារម្មណ៍បង ក្នុងបេះដូងបង ក្នុងសុបិនបងគ្រប់វេលាទាំងអស់ ។

ទេពអប្សរបង ! ស្នាមញញឹមដ៏មានមន្តស្នេហ៍របស់អូន ព្រមទាំងដួងនេត្រាដ៏ស្រទន់មុតថ្លា នៅពេលដែលមកប៉ះនឹងដួង នេត្រាបងម្តងៗ ប្រៀបដូចជាចុងលំពែងយ៉ាងស្រួចមកចាក់ចំបេះដូងរបស់បង ធ្វើអោយបងស្ទើរបាត់វិញ្ញាណទៅហើយ និងបានធ្វើអោយបេះដូងរបស់បង បេះតែដើរខុសចង្វាក់ស្ទើរតែលោតចេញមកក្រៅទៅហើយ ដើម្បីចេញមកសារភាពប្រាប់អូនថា


www.elibraryofcambodia.org

បងស្រឡាញ់អូន បេះដូងបងប្រគល់ជូនតែអូនម្នាក់ ចង់ស្ទុះទៅបីត្រកងថ្នាក់ថ្នមប្រលោមសុំស្នេហ៍អូន តែបងគ្មានសេចក្ដីក្លាហានសារភាពប្រាប់អូនសោះ ។ ហ៊ឺ ! ព្រលឹងមាសបងអើយ ! បងជាមនុស្សកំសាកណាស់ស្រឡាញ់អូនហើយ តែមិនហ៊ានប្រាប់អូន បានត្រឹមតែលាក់ទុកនៅក្នុងបេះដូងដ៏បរិសុទ្ធរបស់បងតែម្នាក់ឯងប៉ុណ្ណោះ ចិត្តបងសែនខ្វាយខ្វល់តែម្នាក់ឯងតែមិនហ៊ានប្រាប់នរណាឱ្យដឹងសោះ ។ ទើបតែថ្ងៃនេះ ដែលបងដាច់ចិត្តកាន់ប៉ាកាបង្ហូរទឹកខ្មៅ ដើម្បីថ្លែងនូវមនោសញ្ចេតនាដែលផុសចេញពីបេះដូងដ៏បរិសុទ្ធរបស់បងដែលមានចំពោះអូន ។ រឿងសេចក្ដីស្នេហារបស់បងចំពោះអូននេះសោត គ្មាននរណាទោះជាអ្នកមានឫទ្ធិបារមីយ៉ាងណាក៏ដោយ ក៏មិនអាចនឹងជួយដោះស្រាយសម្រាលទុក្ខរបស់បងក្រៅពីរូបអូនបានឡើយ ។ បងសង្ឃឹមជឿជាក់ថា ក្នុងលោកនេះ បើមានទេវតាមែន លោកប្រាកដជាយល់ពីសេចក្ដីស្នេហាដ៏បរិសុទ្ធរបស់បងចំពោះអូនមានទំហំធំយ៉ាងណាហើយ ហើយលោកជួយតម្រង់ចិត្តបងនិងអូនឱ្យមានចិត្តថ្លើមដូចគ្នា និងលោកប្រាកដជានឹងជួយតម្រង់ចិត្តរបស់អូនអោយយល់ពីទំហំនៃសេចក្ដីស្នេហារបស់បងចំពោះអូន ថាមានទំហំជម្រៅប៉ុណ្ណាហើយ ។

លក្ខិណាកំពូលដួងចិត្តបង ! តើអូនយល់ព្រមទេ បើសិនជាបងនឹងជំរាបលោកប៉ា អ្នកម៉ាក់បង សូមឱ្យលោកទាំងពីរចូលទៅសុំស្ដីដណ្ដឹងអូនឱ្យបានជាគូគាប់របស់បងអស់អាយុជីវិតតទៅជាអមតៈលុះអវសាន្ត ។ រឿងនេះដូចជាអូនធ្លាប់បានដឹងស្រាប់ហើយថា បូរាណាចារ្យយើងលោកមិនបាច់ឱ្យ

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

គូស្វាមីខ្លួនរវល់គិតគូចំពោះរឿងនេះទេ គេទុកដាក់ ស្រេចទៅលើលោកអ្នកជាមេបាគិតគូរឱ្យទាំងស្រុង ពោលគឺឱ្យកូនប្រុស ស្រី ទាំងគូផ្ញើវាសនាខ្លួនក្នុងរឿងគូស្រករលើលោកឪពុក-ម្តាយតាមតែចំណង់គាត់ទៅ ។ ប៉ុន្តែសំរាប់រូបបងវិញ. បងយល់ថា ត្រូវតែសាមីខ្លួនបានដឹងចិត្តដឹងថ្លើមគ្នាជាមុនខ្លះផង ព្រោះសុភមង្គលរបស់ស្វាមី-ភរិយា តែងកើតឡើងដោយសាររូបបុគ្គលទាំងពីរនេះឯង ចុះបើយើងទាំងពីរមិនទាន់យល់ចិត្តថ្លើមគ្នាដល់តិចតួចសោះ បើបងមិនបានសួរចិត្តអូនជាមុន ហើយអូនក៏មិនទាន់បានយល់ពីចិត្តរបស់បងនៅឡើយ ចុះលោជាថ្ងៃមុខថ្ងៃក្រោយទៅនឹងមានវិបត្តិយ៉ាងណា មុខជាគូស្វាមី-ភរិយានោះហើយ ដែលជាអ្នកទទួលរងបាបគ្រោះ ដូចជាអូនឃើញស្រាប់ហើយ មានគ្រួសារស្វាមីភរិយាខ្លះ រួមរស់នៅជាមួយគ្នាមិនបានយូរប៉ុន្មានផង ក៏ទាស់ទែងលះលែងគ្នាដោយសារតែការមិនបានយល់ចិត្តថ្លើមគ្នាជាមុន ហើយមាតាបិតាទាំងសងខាងចេះតែបង្ខំចាប់ផ្សំផ្គុំគ្នាតាមការយល់ឃើញរបស់គាត់ ។

ទេពធីតាបង ! ដោយយល់ដូច្នេះហើយ ទើបបងដាច់ចិត្តសរសេរសំបុត្រឥតឱ្យនរណាដឹង ដើម្បីផ្ញើមកសួរចិត្តអូនជាមុន ។ បងសង្ឃឹមជាក់ប្រាកដថា អូននឹងតបមកបងឱ្យបានដឹងឆាប់ជាមិនខាន ។

សូមលាសិន លក្ខិណាព្រលឹងមាសបង តែចិត្តបងនៅរង់ចាំជានិច្ចចំពោះសេចក្តីឆ្លើយតបរបស់អូន ។

ដោយចិត្តស្មោះអស់ពីដួងចិត្ត.

**នាក់_សំអឿន**

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

## ២_លិខិតបន្ថែមលើលិខិតខាងលើ ដែលបាត់ដំណឹងសូន្យ មិនឃើញឆ្លើយតប

ផ្ទះលេខ ១៧០B ផ្លូវលេខ ១៦៧. ចំការមន

ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ១៩៩៩

មកដល់លក្ខិណាព្រលឹងមាសបង

លក្ខិណាកំពូលស្នេហ៍របស់បង ! តាំងពីបងផ្ញើសំបុត្រមួយច្បាប់ទៅអូន បងតែងអង្គុយបន់ស្រន់សុំឱ្យព្រះអាទិត្យនឹងព្រះចន្ទ យាងបន្តិ បួររវេនគ្នាឱ្យរហ័សទៅនឹងអាលដល់ថ្ងៃដែលបងបាន ទទួលសំបុត្រពីលក្ខិណាវិញ ប៉ុន្តែ. ប៉ុន្តែខុសស្រឡះ. ខុសស្រឡះពីសេចក្តីប្រាថ្នារបស់បង ហាក់ដូចជាគេបោះដុំគ្រួសទៅក្នុងមហាសាគរ ដែលមានរលកកំពុងបោកវីវក់ សូម្បីតែឮសូរធ្លាក់ក្លុងទៅក្នុងទឹកក៏ឥតបើឮឡើយ ។ លក្ខិណា ! តើអូនដឹងទេថា ចិត្តបងអន្ទះសារទន្ទឹងចាំចម្លើយអូនយ៉ាងណា សំរាប់បងមួយវិនាទី១ ដែលកន្លងទៅវាហាក់ដូចជាមួយសតវត្ស ។ ការចាំបាត់១ មិនឃើញចម្លើយតបរបស់អូនធ្វើឱ្យបងអស់សង្ឃឹមភ្លេចបាយភ្លេចទឹក ។ ឱហ្ន៎ ! សេចក្តីសង្ឃឹមរបស់បងនឹងត្រូវអស់សង្ឃឹមឬអ្វី ? ទោះបីជាយ៉ាងណាក៏ដោយ បងនៅតែសង្ឃឹមជានិច្ចថា មិនទាន់រលាយនៅឡើយទេ។ ព្រោះថា បើសិនជាលក្ខិណាមិនព្រមតាមសំនូររបស់បងទេ មុខជាអូនតបដំណឹងឱ្យបងដឹងផង សោះនឹងសង្ស័យតទៅទៀតមិនខាន ហើយបើអូនព្រមល្មមចិត្តវិញប្រហែលជាអូនតបភ្លាមដែរ

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

ចុះនេះអីក៏បាត់សូន្យឈឹងដូច្នេះ ។

ដោយការរង់ចាំចេះតែមិនឃើញឆ្លើយតប បងបានសម្រេចចិត្តសរសេរសំបុត្រទី២នេះផ្ញើមកស្នើដល់អូនទៀតព្រោះយល់ថា អូនមុខជាដាច់ចិត្តតបមកបងវិញជាមិនខាន ដ្បិតមនុស្សមួយរូប១ ទោះក្តីប្រុសស្រីក្តីកើតមកក្នុងលោក តែងតែមានគូស្រករ ចំណែកលក្ខិណា ក៏ជាមនុស្សលោកដែរ ជាមនុស្សមានបេះដូង មានចិត្តស្រឡាញ់ ត្រូវតែមានគូស្រករចៀសមិនរួច ។

ទីបញ្ចប់នេះ បងសូមបន់ស្រន់ម្តងទៀតសុំឱ្យទេវតាបណ្តាដម្រង់ចិត្តលក្ខិណាសម្រេចចិត្តឱ្យឆាប់១ នឹងអាលដល់ថ្ងៃដែលអូនតបដំណឹងមកបង ហើយបងនឹងបានអានទូវតួអក្ខរៈ ដែលផុសចេញពីដួងចិត្ត និងកើតឡើងពីម្រាមដៃដ៏ទន់ភ្លន់របស់លក្ខិណា ដែលជាទីពេញចិត្តរបស់បងជាយូរមកហើយ ។

សង្ឃឹមជានិច្ច.

**នាក់_សំអឿន**

## ៣_ឆ្លើយតបនឹងលិខិតទាំងពីរខាងលើ

ភ្នំពេញ, ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៥៩

**បងសំអឿនបណ្តូលចិត្តអូន**

សំបុត្ររបស់បងទាំងពីរច្បាប់ អូនបានទទួលហើយ នឹងបានអានទូវសេចក្តីដ៏ផ្អែមល្ហែមរបស់បងហើយ អូនបានអានហើយទៀតមិនចេះស្កប់ស្កល់ ។


www.elibraryofcambodia.org

អូនសុំបងអភ័យទោសដល់បងចំពោះការយឺតយូរ មិនបានតបដំណឹងមកជូនបងវិញឱ្យទាន់ពេលវេលា ។

សំនួររបស់បងទាំងប៉ុន្មាន សុទ្ធតែជាការប្លែកសំរាប់អូនទាំងអស់ ដ្បិតអូនមិនដែលប្រទះនូវសំបុត្រវែលបរិយាយហួរពីរឿងដូច្នេះសោះ ទើបតែឃើញសំបុត្របងនោះបានធ្វើអូនភ្ញាក់ព្រើត ដឹងខ្លួនតែម្តង ។ ខ្លួនបងនឹងអូនក៏ជាមនុស្សធ្លាប់រស់នៅជាមួយគ្នា ធ្លាប់រាប់អានគ្នាយូរមកហើយដែរ សឹងថាបងមិនបាច់សរសេរសំបុត្រ សួរផ្ទាល់មាត់តែម្តងទៅក៏បានដែរ ។ ប៉ុន្តែណ្ហើយចុះបើបងសរសេរមកសួរអូនដល់ទៅពីរទៅហើយ អូនត្រូវតែឆ្លើយជំរាបបងទៅចុះ។ ខ្លួនអូនសព្វថ្ងៃនេះ ក៏បានស្រឡាញ់បងខ្លាំងហោស់ដែរ មិនខុសពីបងស្រឡាញ់អូននោះទេ អូនតែងប្រាប់ខ្លួនឯងថា អូនស្រឡាញ់តែបងម្នាក់ បេះដូងអូនប្រគល់ជូនបងតែម្នាក់ អូនមិនអាចរស់ដោយគ្មានបងបានទេ និងប្រាថ្នាជួបបងគ្រប់ៗ ជាតិ ។ បងជាបុរសដែលមានចរិតសុភាពរាបសារ ស្លូតបូតជាមនុស្សតស៊ូ អំណត់អត់ធន់ខ្ពស់ សំរាប់រូបអូន បងគឺជាបុរសមានអ្វីៗដែលបុរសទាំងឡាយនៅលើលោកនេះមិនមាន ។ បងគឺជាបុរសម្នាក់ដែលបានដក់ជាប់ក្នុងក្រអៅបេះដូងអូន អូនបានថតរូបបងជាប់ក្នុងបេះដូងអូនតាំងពីអូនបានជួបនឹងបងនាទីដំបូងមកម្ល៉េះ ។ ស្នាមញញឹមប្រកបដោយមន្តស្នេហ៍ ដួងនេត្រាដ៏ស្រទន់របស់បង ពេលដែលសម្លឹងចំអូនម្តងៗ ហាក់ដូចជាចុងអាវុធយ៉ាងស្រួចចាក់ចំបេះដូងអូន ធ្វើអោយអារម្មណ៍របស់អូនជ្រួល

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

ប្រេបល់អស់ រកហាស្តីមិនរួច ។ អូនក៏ចង់សារភាពប្រាប់បងវិញដែរ តែអូនជាស្រីមិនអាចសារភាពប្រាប់បងថាអូន ស្រឡាញ់បងនោះបានទេ ។ ហើយម្យ៉ាងទៀត សព្វថ្ងៃនេះអូនពឹងពាក់អាស្រ័យផ្ញើជីវិតលើអ្នកមានគុណទាំងពីរ ឯការទទួលខុសត្រូវចំពោះរឿងរៀបចំឱ្យមានគូស្រករនេះក្តី ក៏អូនមិនអាចទាញយកមកគិតឬសម្រេចផ្ទាល់ខ្លួនដែរ ។ ហេតុនេះ បើសិនជាលោកប៉ា-អ្នកម៉ាក់អូនយល់ព្រមយ៉ាងណា អូននឹងព្រមព្រៀង តាមលោកយ៉ាងនោះដែរ ។ នេះជាទម្លាប់ដែលបងបានសរសេរនៅក្នុងសំបុត្រ បងមុននេះហើយ តែអូនមិនអាចជៀសវាងបានទេ ដ្បិតអូនធ្លាប់បានទទួលការអប់រំរបស់មាតា-បិតាអូនដែលពត់ទៅតាមប្រពៃណីរបស់ជាតិយើងជាខ្មែរ ។

ដូច្នេះ សូមបងកុំប្រកាន់ថាបងមិនរវល់អើពើនឹងរឿងនេះ នោះមិនមែនទេ សូមបងចាត់ការតាមប្រពៃណីរបស់ខ្មែរយើងទៅចុះ អូនឥតយល់ទាស់ទេ ។

អូនសូមលាហើយ អូនសំរាប់បងតែម្នាក់

**ស៊ុម លក្ខិណា**

## ៤. លិខិតផ្ញើទៅគូសង្សារក្រោយពេលស្តីដណ្តឹងរួច

ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៩

មកដល់លក្ខិណាគូជីវិតបង

អូនសម្លាញ់ ! តើអូនដឹងទេ បងគិតថាបងជាមនុស្សម្នាក់ដែលមាន

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

សុភមង្គលនិងសំណាងជាងគេបំផុតនៅលើលោកនេះ ។ ព្រឹកមិញនេះ លោកប៉ាអ្នកម៉ាក់បង គាត់បានចូលទៅស្ដីដណ្ដឹងអូនតាមប្រពៃណី ហើយលោកប៉ានិងអ្នកម៉ាក់អូនក៏បានយល់ព្រមទទួលយកការស្ដីដណ្ដឹងអូនឱ្យបងជាគូជីវិតលុះអវសាន្ត ។ បងមិននឹកស្មានថា សេចក្ដីស្រមៃរបស់បងអាចទៅជាការពិតដូច្នេះសោះ ។ បងសែនសប្បាយរីករាយណាស់គ្មានអ្វីប្រៀបបានទេ ដែលអ្វីៗទាំងអស់ដែលបងប្រាថ្នាចង់បានរូបអូនជាគូជីវិតក្លាយទៅជាការពិត ។ បងសូមសន្យានឹងអូនថា បងនឹងស្មោះចំពោះអូនតែម្នាក់គត់ បងនឹងថ្នាក់ថ្នមអូនឱ្យស្មើនឹងជីវិត បងស៊ូស្លាប់នឹងធ្វើអ្វីៗទាំងអស់ដើម្បីអូន បងនឹងខិតខំធ្វើខ្លួនបងឱ្យក្លាយជាស្វាមីដ៏ល្អរបស់អូននិងជាបិតារបស់កូនយើងទាំងពីរ បងនឹងធ្វើឱ្យជីវិតយើងទាំងពីរមានសេចក្ដីសុខសុភមង្គលជាងគេនៅលើលោកនេះ អូនប្រៀបដូចគ្រាប់ពេជ្រមួយគ្រាប់ដែលមានតម្លៃមិនអាចកាត់ថ្លៃបាន ។ បងសង្ឃឹមថាបេះដូងរបស់អូនប្រគល់ជូនបងតែម្នាក់ ស្មោះតែបងម្នាក់ និងក្លាយជាម្ដាយដ៏ល្អរបស់កូនយើងទាំងពីរ ។

ដោយសេចក្ដីស្មោះពីបង

**ឆាត់-សំអឿន**

www.budinst.gov.kh www.elibraryofcambodia.org

## ៥_លិខិតផ្ញើទៅគូសង្សារដែលឃ្លាតទៅឆ្ងាយ

អាមេរិក. ថ្ងៃទី ៨ តុលា ២០០៣

មកដល់លក្ខិណាគូជីវិតបង

នៅលើពិភពលោកនេះគ្មានអ្វីទេអូន ដែលធ្វើឱ្យបងសប្បាយរីករាយ ដូចបងបានអានសំបុត្ររបស់អូន ដែលប្រកបទៅដោយវាចាដ៏ទន់ភ្លន់ ។ តួអក្សររបស់អូន ហាក់ដូចជាមានវិញ្ញាណឬចេះស្តីប្រាប់បងពីសេចក្តីសុខ-ទុក្ខរបស់អូន នៅឯនាយ ។

តួអក្សរ ! តួអក្សរជាវត្ថុទិព្វឬ ! បានជាចេះធ្វើឱ្យខ្ញុំសប្បាយរីករាយដូចបានជួបមុខអូន ។ តួអក្សរកើតឡើងដោយសាររូបទេពអប្សរណា ? ទេ ! គឺកើតពីចុងម្រាមដៃដ៏ទ្រលុករបស់គូសង្សារខ្ញុំទេតើ ។

ពិតមែនតែអូននិងបងនៅឆ្ងាយពីគ្នា តែវិញ្ញាណនិងចិត្តបងនៅជិតអូនជានិច្ច បងតែងគិត បងតែងមមៃមកដល់អូនគ្រប់ដង្ហើមចេញចូល ។ ពេលវេលាដែលយើងត្រូវជួបគ្នាដើម្បីរស់នឹងគ្នាអស់មួយជីវិតនោះក៏មកជិតដល់ហើយអូន នៅកំបាំងតែមួយខែទៀតទេ ។ ប៉ុន្តែរវាងមួយខែនេះ សំរាប់បងហាក់ជាយូររាប់រយសតវត្សដូច្នោះ ។ រាល់ៗ យប់បងតែងយល់សប្តិឃើញអូន បងតែងនឹកឃើញកាលយើងនៅពីក្មេងនៅផ្ទះជាមួយគ្នា អូនតែងប្រឡែងលេងនឹងបង ហើយសើចកក្អឹក ។ អូន ! ការដែលបងឃ្លាតឆ្ងាយដើម្បីមកបន្តការសិក្សានៅបរទេសនេះ គឺរឹតតែធ្វើឱ្យបងស្រឡាញ់អូន រលឹកអូនកាន់ខ្លាំងឡើងពីមួយថ្ងៃទៅមួយថ្ងៃ ។ ដូច្នេះចូរអូនញញឹមទុក ដើម្បីទទួលនូវ

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

សុភមង្គលរបស់យើងទាំងពីរនៅគ្រាខាងមុខ ណាអូន !

បងសូមលាអូនសិន នឹងសូមផ្ញើចិត្តបរិសុទ្ធមកដល់អូន ។

នាគ់_សំអឿន

## ៦_លិខិតតបនឹងលិខិតខាងលើ

ភ្នំពេញ, ជំនោររាត្រីដ៏ត្រជាក់ថ្ងៃទី១៥ ខែ តុលា ឆ្នាំ ២០០៣

ជូនដល់បង **សំអឿន** បណ្ដូលចិត្តអូន

បង! លិខិតបងពោរពេញទៅដោយមនោសញ្ចេតនារបស់បងដ៏ពិត១ ។ អូនអានហើយ អានទៀតជាច្រើនសាពុំមានធុញទ្រាន់ទេ ។

បងថ្លែងប្រាប់ថា សព្វថ្ងៃបងរលឹកមកដល់អូនណាស់ឥតលស់ខានថ្ងៃណាទេ ត្រង់នេះអូនសុំបញ្ចូលពាក្យដដែលនេះ មកកាន់បងវិញ គឺថាអូនក៏តែងរលឹកមកបងដូច្នេះដែរ ហើយអូនសូមបន្ថែមពាក្យថា លក្ខិណាស្រឡាញ់តែបងអឿនម្នាក់ ស្មោះតែបងម្នាក់ ខ្លួនប្រាណអូនរក្សាទុកសំរាប់តែបងម្នាក់ រាល់ពេលរាត្រីមុនពេលដែលចូលដំណេក អូនតែងអុជធូបបន់ទេពតា បន់ស្រន់សុំឱ្យបងបានជួបតែនឹងសេចក្ដីសុខកុំបីមានជម្ងឺអ្វីមកបៀតបៀនបានឡើយ សូមឱ្យបងនឹកតែអូន ស្រឡាញ់តែអូន ស្មោះតែអូន កុំឱ្យបងស្រឡាញ់នារីណាក្រៅពីអូន អូនខ្លាចដូចសុភាសិតមួយឃ្លាថា "ឃ្លាតឆ្ងាយណាយចិត្ត ឬបានស្វាយណាយក្រូច" ណាបង ។ និងសូមឱ្យពេលវេលាមួយខែនេះកន្លងទៅឱ្យឆាប់១ អូននឹងអាលបានជួបមុខបង ។


www.elibraryofcambodia.org

ទីបំផុតនេះ អូនសូមផ្ញើមកជូនបងនូវសេចក្តីនឹករលឹកក្រៃលែង នឹងទឹកចិត្តដ៏បរិសុទ្ធរបស់អូនមកដល់បង ។

អូនរង់ចាំបងនិងនឹករលឹកដល់បងជានិច្ច
អូនជាកម្មសិទ្ធិរបស់បងតែម្នាក់លុះអវសាន
ស៊ុម_លក្ខិណា

## ៧_លិខិតផ្ញើទៅមិត្តនារី

ភ្នំពេញ, ថ្ងៃទី ៥ កញ្ញា ១៩៩៩

អូន**លក្ខិណា** ជាទីស្នេហា !

អូនសម្លាញ់ ! បងមានសេចក្តីរីករាយណាស់ ដោយបានចារអក្ខរាមួយជូនអូន ដើម្បីប្រាប់អូនឱ្យដឹងថា បងស្រឡាញ់អូនណាស់ ជាតិនេះបងមិនអាចគ្មានអូនបានទេ ។ ព្រលឹងមាសបង គ្មានអ្វីមួយ ដែលមានអំណាច មកបំបែកបងចេញពីអូនបានឡើយ ។ ស្នេហារបស់យើង នឹងឋិតនៅលើគុណធម៌ ព្រមទាំងមានអាយុយឺនយូរជាអមតៈ ។ ស្នេហ៍យើងថ្វីត្បិតតែទើបនឹងរីកឡើងថ្មីៗក៏ដោយ ក៏បញ្ចេញនូវការកក់ក្តៅ មិត្តភាព ហើយនឹងការយល់ចិត្តថ្នមគ្នាយ៉ាងស្មោះស្ម័គ្ររវាង ។ តាំងពីយើងទាំងបានធ្លាក់ទៅអន្លង់នៃសេចក្តីស្នេហាចំពោះគ្នាទៅវិញទៅមក យើងបានដឹងក្នុងចិត្តជានិច្ចថា ស្នេហាយើងហាក់ដូចជាតូរ្យតន្ត្រីដែលប្រគំឡើងត្រូវសង្វាក់គ្នាយ៉ាងពិរោះ ។

ស្នេហារបស់យើងបរិសុទ្ធជាងអ្វីទាំងអស់ ពោលគឺជាស្នេហាដ៏ប្រសើរមានន័យជាងគេបំផុតក្នុងលោក ។ យើងនៅតែស្នេហ៍រវាងគ្នានឹងគ្នា រហូតដល់-

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

សមុទ្រទាំងអស់រីងស្ងួតជាថ្ម មេឃរលំ ភ្នំរលាយក្លាយជាទឹក ។

បងតែងតែសុបិនឃើញអូន យល់សប្តិឃើញថ្ងៃដ៏សុខដុមខិតចូលមកដល់ ។ បងសុបិនឃើញ គេហដ្ឋានដ៏ស្តុកស្តម្ភ ដោយមានសួនច្បាររីកស្គុះស្គាយ ហើយដែលនៅទីនោះ អូននឹងរួមរស់ជាមួយបង លុះអវសាន្ត ។ អូនបណ្តូលចិត្តបង បងសុបិនឃើញអូនគ្រប់ទិវារាត្រី ។ បងតែងតែចង់ឋិតនៅជាមួយអូនជានិច្ច បើមិនបាននៅជិតខ្លួនប្រាណទេ អោយតែជាប់ក្នុងសតិអារម្មណ៍អូនក៏បានដែរ ។ រួចបងដើរក្នុងផ្លូវនានា ដើរក្នុងសួរសាធារណៈ ហើយយូរៗ ម្តងបងទាញរូបថតអូនមកគយគន់ហើយញញឹមដាក់វា ។ អ្នកផងទាំងពួង សម្លឹងមើលបង ។ គេយល់ថាបងឆ្កួត ។ ប៉ុន្តែទុកអោយបង ប្រាប់អាថ៌កំបាំងមួយដល់អូនណាសម្លាញ់ដួងចិត្តបង ! ។ បងឆ្កួត ឆ្កួតព្រោះតែស្រឡាញ់អូន ។

បងសង្ឃឹមថា អាពាហ៍ពិពាហ៍របស់យើង នឹងប្រព្រឹត្តទៅនៅក្នុងពេលឆាប់ៗ នេះហើយ ហើយបងនឹងបានបីត្រកងថ្នាក់ថ្នមអូន ក្នុងរង្វង់ហត្ថាដ៏ស្រោលៗ និង លើដើមទ្រូងដ៏ទន់ភ្លន់របស់អូន ។

អូនកំពូលស្នេហ៍បង ! បងសូមបញ្ចប់សំបុត្រត្រឹមនេះចុះ បងសូមសន្យាថា នឹងសរសេរជូនអូនច្រើនជាងនេះទៅទៀត ។

អ្វីៗ សំរាប់តែអូនម្នាក់ !

ជាកម្មសិទ្ធិរបស់អូនលុះអវសាន្ត

**នាគ់ សំអឿន**

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

# ៨-លិខិតផ្ញើទៅគូកំណាន់ចិត្ត

ភ្នំពេញ. ថ្ងៃទី ១៦ តុលា ១៩៥៩

**លក្ខិណា** ទេពអប្សររបស់បង !

អូនសំឡាញ់, បងនឹកអូនណាស់ មិនបានជួបអូនមួយថ្ងៃ ប្រៀបដូច បងមិនបានជួបអូនរាប់រយសតវត្សអញ្ចឹង តាមការពិត ការឋិតនៅឆ្ងាយ ពីអូនពេក ធ្វើឱ្យបងស្ទើរតែទ្រាំមិនបាន ។ ពេលបងបានជួបមុខអូនម្តង១ វាធ្វើអោយបេះដូងបងស្ទើរតែលោតខុសចង្វាក់ទៅហើយ បងមានអារម្មណ៍ រំភើបខ្លួនបងឡើងស្រាល ស្ទើរតែហោះទៅបីត្រកងថ្នាក់ថ្នមអូនពីចម្ងាយ ហើយបញ្ហាស្មុគស្មាញ ការលំបាកចិត្តទាំងឡាយ វាបានរសាយអស់រលីង ពីខ្លួនរបស់បង និងកាន់តែធ្វើអោយបងមានកម្លាំងចិត្តតស៊ូនឹងបញ្ហាជីវិត ។ ដើម្បីបានជួបអូនបងហ៊ានពុះពារគ្រប់ឧបសគ្គ បងហ៊ានលះបង់អ្វី១ទាំងអស់ សូម្បីតែជីវិតរបស់បង ។ បងមានសេចក្តីរីករាយណាស់ ដោយដឹងថា នៅតែបួនថ្ងៃទៀតទេ យើងនឹងទៅកំសាន្តនៅឆ្នេរខ្សាច់ជាមួយគ្នា ។ ពេលនោះអូននឹងដឹងថា តើបងស្នេហ៍អូនដល់កំរិតណា ! ។ ប៉ុន្តែ រយៈពេលបួនថ្ងៃវាហាក់ដូចជាយូរណាស់សំរាប់បង ពីមួយវិនាទីទៅមួយ វិនាទីធ្វើឱ្យបងកាន់តែចង់ជួបអូនខ្លាំងឡើង ។ ពេលថ្ងៃបងបន់ឱ្យតែ ព្រះសូរិយាឆាប់លិច ហើយពេលយប់បងបន់ឱ្យតែឆាប់ភ្លឺអាលនឹងដល់ថ្ងៃ

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

បងបានជួបភក្ត្រារបស់អូន ។ ពៅព្រលឹងបង ! តើអូនដឹងទេ គ្រប់វិនាទីបងតែងតែនឹកស្រមៃដល់អូនជានិច្ច ជាពិសេសរៀងរាល់រាត្រីបងតែងតែសុបិនឃើញថ្ងៃដែលយើងបានជួបគ្នានៅថ្ងៃខាងមុខ គឺសុបិនឃើញថាយើងទាំងពីរបណ្តើរគ្នាតាមឆ្នេរខ្សាច់ សាសងអូនបងផ្អែមល្ហែម ហើយអូនបានវាចាទាំងទន់ភ្លន់ចេញពីបេះដូងបរិសុទ្ធរបស់អូន ប្រាប់បងអូនថា អូនស្រឡាញ់តែរូបបងមួយគត់ក្នុងជាតិនេះស្មើជីវិតរបស់អូន និងយើងទាំងពីរនាក់នាំគ្នាពូនភ្នំខ្សាច់ប្រណាំងគ្នា សើចកក្អាកកក្អាយ ហើយយើងទាំងពីរគេងនៅក្នុងរូបបេះដូងដែលយើងទាំងពីរបានគូរលើឆ្នេរខ្សាច់ព្រមជាមួយភ្លើងទៀនក្រោមពន្លឺនៃដួងចន្ទ្រាដ៏ស្រទន់ ។ បងតែងបន់ស្រន់បួងសួងសូមអោយសុបិន្តរបស់បង ក្លាយជាការពិត ។

សូមអូនឧស្សាហ៍សរសេរសំបុត្រមកបងអោយបានរឿយៗ កុំបីខាន។ អូនដឹងទេ ពេលដែលបងបានអានអក្សរដែលកើតចេញពីចុងម្រាមដៃដ៏ទ្រលុកព្រមទាំងអក្ខរាដែលផុសចេញអំពីបេះដូងដ៏បរិសុទ្ធរបស់អូនម្តងៗ ប្រៀបដូច ជាបងបានជួបភក្ត្រអូន ឃើញស្នាមញញឹមដ៏មានមន្តស្នេហ៍របស់អូន ។ សំបុត្ររបស់អូនមួយច្បាប់ៗ ហាក់ដូចជាមានវិញ្ញាណឬក៏ចេះស្តីប្រាថ់បងពីមនោសញ្ចេតនារបស់អូនប្រាប់បង បងបានអានហើយអានទៀត មិនចេះស្កប់ស្កល់ ។

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

សូមអូនជ្រាបថា បងទន្ទឹងរង់ចាំអូនគ្រប់ថ្ងៃ, គ្រប់ម៉ោង, គ្រប់នាទីទាំងអស់ ! ជឿបងចុះ, អូនបណ្តូលចិត្តបង ! នេះជាពាក្យពិត !

ដោយចិត្តស្នេហាទាំងស្រុងរបស់បងចំពោះអូនសំឡាញ់ !

ជាកម្មសិទ្ធិរបស់អូនតែម្នាក់គត់លុះគ្រប់ជាតិ !

**នាក់ សំអឿន**

## ៩_លិខិតតបទៅលិខិតខាងលើ

បង។ **សំអឿន** កំពូលស្នេហ៍អូន !

បងសម្លាញ់ ! អូនបានទទួលសំបុត្ររបស់បងពោរពេញទៅដោយមនោសញ្ចេតនាហើយ អក្ខរាដែលចារចេញពីបេះដូងដ៏បរិសុទ្ធរបស់បងធ្វើអោយអូនកាន់មានសេចក្តីស្នេហ៍ចំពោះបងកាន់តែខ្លាំងឡើង ៗ រហូតដល់អូនបានតែនិយាយប្រាប់ខ្លួនឯងថា ជាតិនេះអូនមិនអាចគ្មានរូបបងបានឡើយ និងសូមប្រាថ្នាអោយបានជួបបងគ្រប់ៗ ជាតិ ។ បងសម្លាញ់ ! បងដឹងទេ ចិត្តស្រឡាញ់របស់អូនចំពោះបង ក៏មិនខុសពីសេចក្តីស្រឡាញ់ដ៏បរិសុទ្ធរបស់បងចំពោះអូនដែរ ។ អូនតែងបន់ស្រន់អោយឆាប់ដល់ថ្ងៃដែលបានជួបមុខគ្នានៅឆ្នេរខ្សាច់នៅក្រុងព្រះសីហនុមកដល់ឆាប់ទេ ។ អូនក៏តែងនឹកគិតដល់បងគ្រប់វិនាទីដែរ អូនតែងសុបិនឃើញបងរៀងរាល់ទិវារាត្រី និងអូនតែងសុបិន

www.budinst.gov.kh www.elibraryofcambodia.org

ឃើញដល់ថ្ងៃមង្គលការយើងទាំងពីរនាក់ ដ៏សែនមានសុភមង្គលជាងគេ នៅក្នុងលោកនេះ ។

ក្នុងរវាងបួនថ្ងៃខាងមុខនេះ គឺជាដំណើរកំសាន្តរបស់យើង ការជួបគ្នានោះនឹងសប្បាយពេកណាស់ ! នៅពេលនោះ យើងរ៉ាយរ៉ាប់ពីជំរៅបេះដូងរបស់យើងទាំងពីរប្រាប់គ្នាទៅវិញទៅមក ហើយយើងនឹងបានបង្កើតនូវអនុស្សាវរីយ៍រាប់ម៉ឺនសែនជាមួយគ្នា ។ ចំពោះរឿងសរសេរឱ្យបានញឹកញាប់វិញ អូនពុំអាចឈប់ស្ងៀមបានឡើយ អូននឹងសរសេរហើយសរសេរទៀត ! ដូច្នេះ សូមបងបណ្ដូលចិត្តអូនរង់ចាំមើលផ្លូវអ្នកនាំសារជាទីសំណប់ចិត្តរបស់បងចុះ !

បងអឿន កំពូលស្នេហ៍អូន ! អូននឹកមមៃមកដល់បងគ្រប់ពេលវេលា!

ដោយចិត្តស្នេហាដ៏បរិសុទ្ធចំពោះបង !

**ស៊ុម_លក្ខិណា**

## ១០_លិខិតផ្ញើទៅគូសង្សារ

ផ្ទះលេខ ១៧០B, ផ្លូវលេខ ១៦៧, ភ្នំពេញ

ថ្ងៃទី ១២ ខែមិនា ឆ្នាំ ១៩៩៩

បង **សំអឿន** កំពូលស្នេហ៍អូន !

ក្នុងលោកនេះ អូនយល់ថា ក្រៅពីលិខិតរបស់បងគ្មានអ្វីធ្វើឱ្យអូន

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

សប្បាយរីករាយបានទេ ។ លិខិតបងធ្វើអោយការរស់នៅរៀងរាល់ថ្ងៃរបស់អូន ពោរពេញទៅដោយពន្លឺរស្មីចិញ្ចែងចិញ្ចាច និងប្រកបដោយសេចក្ដីសប្បាយរីករាយជានិច្ច ។

ក្នុងពេលកន្លងទៅថ្មីៗ នេះ តើបងបានឮអូនប្រាប់ថា អូនស្នេហ៍បងទេ ? រូបបងស្ថិតនៅក្នុងសោតិន្ទ្រិយរម្មណ៍របស់អូន គ្រប់វិនាទីនៃទិវា និងឋិតជាប់ក្នុងសុបិនអូន រាល់ពេលម៉ោងនៃរាត្រីកាល ។ អូនតែងទន្ទេញឈ្មោះបងនៅក្នុងចិត្តអូនជានិច្ច និងតែងទន្ទេញតែពាក្យថាអូនស្នេហ៍បងរហូតពីព្រឹកមិញនេះ នៅពេលកំពុងសរសេរតាមអានក្នុងថ្នាក់ អូនស្ទើរតែសរសេរពាក្យថា "អូនស្នេហ៍បងតែម្នាក់" នៅលើក្រដាសកិច្ចការ ក្រោមក្រសែចក្ខុនៃលោកគ្រូតែម្ដង ។ តែដោយសំណាងល្អ លោកគ្រូអូនគាត់មិនបានចាប់អារម្មណ៍ ដល់ការជ្រួលច្របល់ក្នុងចិត្តរបស់អូនឡើយ ។

អូនបានចំណាយពេលទំនេរស្ទើរតែទាំងអស់ នៅក្នុងហាងលក់ថាសចំរៀង ដើម្បីរកមើលចំរៀងសំណប់ចិត្តរបស់យើង ។ ថាសចំរៀងដែលបងបានផ្ញើឱ្យអូននោះ ឥឡូវវាស្ទើរតែសឹករិចរិលអស់ទៅហើយ ដោយសារតែអូនចាក់វាហើយចាក់ទៀត ។

តើបងនៅចាំរាត្រីដែលយើងទាំងពីរបានស្ដាប់ថាសចំរៀងជាលើកដំបូងនៅក្រោមពន្លឺដួងព្រះចន្ទ្រាដ៏ស្រទន់ប្រៀបដូចជាស្នេហ៍យើងទាំងពីរ

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

នោះទេ? ភ្លេងនិងចំរៀងពិរោះនោះ ធ្វើអោយអូនមានសេចក្ដីសុខណាស់ និងធ្វើឱ្យអូននឹកឃើញដល់អនុស្សាវរីយ៍រាប់មិនអស់របស់យើង ដែលបានសាងជាមួយគ្នា ។

បងដឹងទេ ដោយគ្រាន់តែអានសំបុត្របងភ្លាម អូនស្រមៃហាក់បានឃើញរូបបងនៅទីនោះជាមួយអូនអីចឹង ! ហើយដោយគ្រាន់តែការនឹកស្រមៃរបស់អូននឹកដល់បងភ្លាម អូនក្លាយទៅជានារីម្នាក់ដែលមានសេចក្ដីសុខជាងគេបំផុតក្នុងលោកនេះ ។

សូមបងរក្សាខ្លួនអោយបានល្អ ហើយនឹងសូមឱ្យស្នេហ៍យើងមានជីវិតជាអមតៈរៀងរហូតតទៅ !

ដោយសេចក្ដីស្នេហាយ៉ាងខ្លាំង

**ស៊ុម_លក្ខិណា**

## ៧_លិខិតតបនឹងលិខិតខាងលើ

**លក្ខិណា**កំពូលស្នេហ៍បង !

លក្ខិណាព្រលឹងស្នេហ៍បង ! នៅលើលោកនេះគ្មានអ្វីទេអូន ដែលធ្វើឱ្យបងមានសេចក្ដីសុខស្មើនឹងបងបានអាននូវអក្ខរាដែលកើតឡើងម្រាមដ៏ទ្រលុកស្រឡូនរបស់អូនពោរពេញទៅដោយមនោសញ្ចេតនាដ៏បរិសុទ្ធរបស់អូនដែលមានចំពោះបង ។ សំបុត្រអូនល្អណាស់ រហូតដល់បង

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

អានហើយអានទៀតមិនចេះ ស្កប់ស្កល់ ។

វាចាថាអូនស្នេហ៍បងដ៏សែនពិរោះ វាស្ថិតនៅជាប់ក្នុងអារម្មណ៍បងជានិច្ច។ បងមានសេចក្ដីសុខណាស់ ដោយដឹងថា សំបុត្ររបស់បងបាននាំនាំយកនូវសេចក្ដីសប្បាយ និងសេចក្ដីសង្ឃឹមមកអោយអូន និងបងបានទទួលសំបុត្រព្រមទាំងចម្លើយរបស់អូនថា អូនស្នេហ៍បងៗ ។ បងនឹងសរសេរសំបុត្រអោយបានច្រើនថែមទៀត ក្នុងពេលយ៉ាងខ្លីខាងមុខនេះ ។

អូនកំពូលស្នេហ៍បង ! គ្មាននរណាម្នាក់ចង់អោយកូលាបដែលគេស្រឡាញ់អស់ពីដួងចិត្ត រុះរោយ ឬ ស្វិតស្រពោនទៅណាទេ ជាពិសេសរូបបងផ្ទាល់ ណាព្រលឹងបង ! គឺបងនឹងរក្សាអោយកូលាបរបស់បងនៅតែរីកក្រពុំ ស្រស់ស្រាយ និង ស្រស់ញញឹមជានិច្ច ។

ដូច្នេះ សូមទេពអប្សររបស់បង អូនជឿបងចុះ ! បងនឹងធ្វើនូវអ្វីទាំងអស់ ដើម្បីអោយអូនបានសប្បាយ និងអោយអូនបានរស់នៅក្នុងជីវិតដ៏សែនរីករាយ ក្នុងពិភពលោកនេះ ។

បងសូមថើបអូនមួយលានដងចំពោះពាក្យថា "ស្នេហ៍" នោះ ។ បងដឹងច្បាស់ថា ពាក្យនោះចេញពីជម្រៅដួងចិត្តដ៏បរិសុទ្ធរបស់អូន ។ បងជឿអូនហើយ ហើយបងស្នេហ៍អូន ខ្លាំងជាងពេលណាៗ ទាំងអស់ ។ អូនសម្លាញ់បង ! បងមិនអាចរកពាក្យពេចន៍ត្រឹមត្រូវល្អមកថ្លាថ្លែងនូវស្នេហា

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

ដ៏ធំធេង របស់បងចំពោះអូនបានឡើយ ។

ស្នេហ៍របស់បងចំពោះអូន ៗ មានជម្រៅជ្រៅជាងមហាសាគរទាំងអស់ក្នុងលោកយើងនេះ មានកំពស់ខ្ពស់ជាងភ្នំព្រះសុមេរុ មានឱជារសផ្អែមល្ហែមជាងទឹកឃ្មុំ មានសម្ផស្សល្អជាងផ្កាកូលាបទៅទៀត ហើយបងប្រគល់ស្នេហ៍ទាំងអស់នោះជូនអូនដោយសុទ្ធចិត្ត គ្រប់ដង្ហើមចេញចូលរបស់បង គ្រប់ជំហានទៅមករបស់បង គ្រប់វិនាទីនៃទិវារាត្រី បងតែងនឹកមមៃទៅដល់អូនជានិច្ច ។ រូបអូនឋិតក្នុងសតិអារម្មណ៍បង ក្នុងបេះដូងបង ក្នុងសុបិនបងគ្រប់វេលាទាំងអស់ ។

យប់មិញនេះ បងបានស្តាប់ចំរៀងក្នុងវិទ្យុ បងបានឮចំរៀងមួយបទដែលអូនផ្ញើជូនបង ចំរៀងនេះរៀបរាប់រឿងស្នេហ៍របស់អូនចំពោះបង អូនថាអូនស្រឡាញ់តែបងតែម្នាក់ ។ សូមអូនផ្ញើពាក្យនោះមកអោយបងទៀតកុំខាន ណាំអូនមាសស្នេហ៍បង ។ បងឥតមានការនឿយណាយនឹងស្តាប់វាចារបស់អូនឡើយ ។

បងក៏ដូចជាអូនអញ្ចឹងដែរ អូនបណ្តូលចិត្តបងអើយ ! បងច្រើនតែថាត្រាប់តាមពាក្យ "អូនស្នេហ៍បង១" យ៉ាងខ្លាំង១ ក្នុងបន្ទប់បង បងថាត្រាប់តាមដោយទាំងមិនដឹងខ្លួនផង ពេលខ្លះ បងយល់ថា បងប្រៀបដូចជាមនុស្សឆ្កួតទៅហើយ ព្រោះស្រឡាញ់អូន នឹកអូន គិតដល់អូន

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

ប្រាថ្នាចង់បានអូនមកបីត្រកងថ្នាក់ថ្នមឆាប់ៗ។

ចំពោះបង មាសព្រលឹងបងអើយ ! បងសូមស្វាគមន៍វាចាទាំងនោះដោយចិត្តស្មោះស ពីព្រោះវាជាសំដីរបស់អូនដ៏សែនពីរោះ ដែលផុសពីបេះដូងបរិសុទ្ធរបស់អូន ។

ពៅព្រលឹងបងអើយ !សូមអូនជឿលើចិត្តបងចុះ ហើយសូមអូនរៀបខ្លួនប្រាណជាស្រេច ដើម្បីទទួលស្វាគមន៍ ប៉ាម៉ាក់បងនៅផ្ទះអូន នៅពេលឆាប់ៗ ខាងមុខនេះ ។

ដោយចិត្តស្មោះអស់ពីដួងចិត្តអំពីបង

**នាក់_សំអឿន**

## ១២_លិខិតសូមទោសគូកំណាន់ចិត្ត

ភ្នំពេញ,ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៨

អូន **លក្ខិណា** បណ្តូលចិត្តបង !

បងទទួលសារភាពថា បងខុសហើយដោយបានសរសេរពាក្យទោសោ មោហោបែបហ្នឹងមកជូនអូន ។ បងចំជាភ្លីភ្លើងមែន, រឿងហ្នឹងមកតែពីបង បានស្រឡាញ់អូនស្មើនឹងជីវិតបងទៅហើយ និងបាត់រូបអូនមិនបាន ហើយបែរជាបានឃើញអូនបណ្តើរប្រុសផ្សេងបញ្ឈឺបង ។ ប៉ុន្តែ

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

ក្រោយមកទើបបងបានដឹងថា បុរសម្នាក់នោះ គឺជាបងជីដូនមួយអូនទេ ។ អូនសម្លាញ់ ! បងសូមទោស បងមិនដែលមានបំណងបញ្ចប់រឿងស្នេហារបស់យើងទាល់តែសោះហើយ ។ បងសូមសន្យាថា បងលែងខឹងនឹងអូនទៀតហើយ ព្រោះថាស្នេហាយើងកំពុងរីកចំរើនឡើងរៀងរាល់ថ្ងៃ ។

សូមអូនអភ័យទោសឱ្យបងផង ហើយកុំទុករឿងនេះក្នុងចិត្តអី និងសូមអូនសរសេរមកបង ហើយប្រាប់បងថា អូនអោយអភ័យដល់បងហើយ វាគឺកំហុសរបស់បងទាំងស្រុង ដែលនាំអោយយើងទាំងពីរ ឈ្លោះប្រកែកគ្នានោះ ហើយបងឈឺចាប់ស្ទើរប្រេះទ្រូងស្លាប់ទៅហើយ ដោយក្ដីស្នេហ៍របស់បងបានធ្វើអោយអូន មានការមិនសប្បាយចិត្តនោះ ។

ព្រលឹងមាសបង ! នេះមិនមែនមកពី បងមិនស្រឡាញ់អូននោះទេ តែផ្ទុយទៅវិញ មកពីបងស្រឡាញ់អូនខ្លាំងហួសពេកមិនអាចនឹងរកអ្វីមកមកប្រៀបផ្ទឹមបាន ។ ដោយសារតែសេចក្ដីស្រឡាញ់របស់បងចំពោះអូនមានជម្រៅមិនអាចវាស់បាននេះ ដែលធ្វើអោយបងកើតមានចិត្តប្រច័ណ្ឌរហូតដល់បងគ្រប់គ្រងអារម្មណ៍របស់បងមិនបាន ហើយបានប្រើពាក្យមិនគួរគប្បីចំពោះអូន ។

សូមអូនប្រាប់បងថា អូននៅតែស្រឡាញ់បងនៅដដែល ដូចបងស្រឡាញ់និងគោរពអូនដូច្នោះដែរ ព្រោះថាបើ ប្រាសចាកក្ដីស្នេហ៍ពីអូន

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

បងក៏ក្លាយទៅជាមនុស្សរស់នៅតែគ្មានវិញ្ញាណដូច្នោះដែរ ។

ដោយសេចក្តីស្នេហ៍ស្មោះពីបង

**នារ៉ា សំអឿន**

## ១៣_ លិខិតបដិសេធនិងពាក្យសុំរៀបការ

ភ្នំពេញ, ថ្ងៃទី ២៤ កក្កដា ១៩៩៨

បងសម្បត្តិជាទីរាប់អាន

សូមបងជឿអូនចុះ នេះគឺជាលិខិតមួយដែលនឹងពិបាករ៉ាយរ៉ាប់ណាស់ ។ អូនបានគិតសព្វគ្រប់អស់ហើយ គឺគិតហើយគិតទៀតនៅពេលដែលអូនសរសេរនោះ ប៉ុន្តែនៅទីបំផុត អូនបានមកដល់សេចក្តីបញ្ចប់មួយដែលថាវិធីប្រសើរបំផុតក្នុងការឆ្លើយតបនឹងសំបុត្របង គឺត្រូវឆ្លើយចំៗដោយឥតលាក់លៀមអ្វីនឹងបងឡើយ ។

អូនមិនអាចរៀបការនឹងបងបានទេ ។

អូនមិនអាចរៀបការនឹងបងបានទេ ពីព្រោះអូនដឹងក្នុងចិត្តស្រេចហើយថា យើងទាំងពីរមិនអាចរស់នៅជាគូស្រករនឹងគ្នាបានយូរលង់ឡើយ ។ មានឱកាសច្រើនណាស់ ដែលអូនបានកត់សំគាល់ឃើញថា មានកិច្ចការខ្លះកើតឡើង ហើយវាបង្ហាញអោយឃើញថា យើងមានគំនិតផ្ទុយ

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

គ្នាស្រឡះ ព្រមទាំងមានប្រតិកម្មផ្សេងពីគ្នាស្រឡះទៀត ។ បើនិយាយមួយបែបផ្សេងទៀត គឺអូនដឹងក្នុងចិត្តថា បើអូនយល់ព្រមតាមការស្នើរបស់បងអោយអូនរៀបការនោះឃើញថា ការរស់នៅជាប្តីប្រពន្ធរបស់យើង នឹងគ្រាន់តែក្លាយទៅជាការជជែកយកឈ្នះចាញ់ នឹងការមិនចុះសម្រុងគ្នាជាហូរហែមិនចេះចប់ឡើយ ។

បងសម្បត្តិ ! តើបងដឹងទេ ? អ្វីទៅជីវិតស្វាមីភរិយាដែលរស់នៅប្រកបដោយសុភង្គលនោះ ? គឺមិនមែនរៀបការដើម្បីបំពេញការសប្បាយរបស់ខ្លួននោះទេ ពោលគឺបើចង់រស់នៅមានសុភមង្គលលុះអវសាន្ត លុះត្រាតែបងនិងអូនយល់ចិត្តថ្លើមគ្នាទៅវិញ យល់ពីតំលៃនៃសេចក្តីស្នេហា មានចិត្តស្មោះនឹងគ្នាទៅវិញទៅមក ចេះអធ្យាស្រ័យឱ្យគ្នាទៅវិញទៅមក មិនចាំបំណាំគ្នា មិនចាត់ទុកភរិយាគ្រាន់តែជាទាសីរបស់ខ្លួន និងមានប្រការជាច្រើនទៀត ។

ដូច្នេះ អូនសូមបញ្ចប់រឿងយើងទាំងពីរត្រឹមនេះចុះ វាប្រសើរជាងបណ្តោយជីវិតរបស់យើងទាំងពីរមានការគ្រាំគ្រាចិត្តខ្លាំងជាងនេះ ហើយធ្លាក់ទៅក្នុងអន្លង់មួយសែនជ្រៅមិនអាចងើបរួច ។ ថ្វីបើពេលនេះអូនទទួលការឈឺចាប់បន្តិចមែន តែវាប្រសើរជាងអូនរស់នៅក្នុងសមុទ្រទឹកភ្នែករបស់បងទៅអនាគតដែរ ។

www.budinst.gov.kh www.elibraryofcambodia.org

អូនសង្ឃឹមថា សេចក្ដីបដិសេធនេះ មិនធ្វើអោយបងឈឺចាប់ទេ ហើយមិនធ្វើអោយបងខូចខាតដល់មិត្តភាពរបស់យើងឡើយ ។ អូនជឿជាក់ក្នុងចិត្តទៀតថា នៅមានស្ត្រីជាច្រើនទៀត នឹងអាចធ្វើជាភរិយាដ៏ល្អរបស់បងជាងរូបអូនទៅទៀត ។

ដោយរាប់អានពីអូន

ចាន់ សម្ផស្ស

## ១៤_លិខិតលាយដោយកំហឹង ដែលបុរសម្នាក់ផ្ញើទៅមិត្តនារី

ភ្នំពេញ, ថ្ងៃទី ២៣ សីហា ១៩៩៨

**មកដល់អូនសម្ផស្ស**

អូនសម្ផស្ស ! មុនដំបូងបងសូមអភ័យទោសអំពីអូន ពុំគួរបងហ៊ានសរសេរសំបុត្រមិនគួរគប្បី ខុសចាកប្រពៃណីខ្មែរ ចាកការគួរសមពីច្បាប់សុជីវធម៌ និងដំបូន្មានមករកអូនក្នុងពេលនេះសោះ ។

សម្ផស្ស ហេតុអ្វីបានជាអូនគ្មានចិត្តមេត្តា មិនព្រមទទួលសេចក្ដីស្នេហាពីបងផង ? ប្រហែលជាអូនយល់ច្បាស់ថា បងជាមនុស្សអន់ខ្សោយ កំសាកគោងកាច ប្រឡើសបើស ព្រានទនារី ប្រឡោងខាមណាស់ទៅឬ? បងមិនអាចស្វែងរកសុភមង្គល រកប្រាក់ខែ រកឡានបញ្ជិះអូនដើរលេងសង្ហារមិនបានឬ ?

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

អូនសម្ងួស្ស ឆ្លើយយ៉ាងខ្លីមក អោយរសាយធូរទ្រូងបងផង !

អូនមិនយល់ទេឬ ? បងខំរៀនដល់ជាប់សញ្ញាប័ត្រវិស្វករជាន់ខ្ពស់ ដើម្បីនរណា ? មិនគឺដើម្បីសម្ងួស្សនេះឯង ?

សញ្ញាប័ត្រនេះ ជាសេចក្ដីសុខចំពោះសម្ងួស្សហើយតើ !

ពេលនេះ បែរជាអូនបដិសេធមិនព្រមរៀបការនឹងបងវិញ... បងក្លាយទៅជាមនុស្សអភ័ព្វ ។ ឯរឿងដែលបងមិនយកចិត្តទុកដាក់នឹងអូន មិនអាចបំពេញតាមបំណងរបស់អូនពីមុនមក គឺមកពីពេលនោះ បងស្ថិតនៅក្នុងការសិក្សានៅឡើយ ជីវិតអ្នកសិក្សាមិនអាចយកស្នេហាមកលាយឡំបានទេ បើនរណាម្នាក់កំពុងសិក្សាហើយមានស្នេហាមកលាយឡំជាមួយនោះ វាធ្វើអោយអ្នកនោះ រៀនមិនបានសំរេចរហូតដល់ចប់បានទេ ដូចជាមានសុភាសិតខ្មែរមួយឃ្លាបានពោលថា "ស្នេហាគឺជាសត្រូវនៃការសិក្សា" ។ ថ្វីត្បិតតែពេលនោះ បងមិនសូវរវល់នឹងអូនក៏ដោយ ប៉ុន្តែក្នុងចិត្តរបស់បងមានតែអូនម្នាក់ស្រឡាញ់តែអូនម្នាក់ បងតែគិតដល់អូនគ្រប់វិនាទី បងស្មោះតែអូនម្នាក់បេះដូងរបស់បងប្រគល់ជូនអូនតែម្នាក់ ។ អូនតែងនិយាយថា បងមិនយល់ចិត្តរបស់អូននោះ មិនពិតទេ តាមពិតបងយល់ណាស់ថា អូនស្រឡាញ់បងខ្លាំងណាស់ អូនត្រូវការបងនៅជិតអូន ថ្នាក់ថ្នមអូន សាសាងរកអូនគ្រប់វិនាទី អូនចង់រស់នៅជាមួយបងប្រកបដោយសុភមង្គល ទាំងអស់នេះបងយល់ ប៉ុន្តែធ្វើម៉េចទៅអូនអើយ បើពេលនេះ បងមិនទាន់បានបញ្ចប់ការសិក្សា

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

នៅឡើយ បងមិនទាន់មានសមត្ថិភាពរកសុមង្គលជូនអូននៅឡើយ ។ ប៉ុន្តែ បងសូមសន្យាថា ពេលដែលបងរៀនចប់ហើយ បងនឹងរៀបការជាមួយអូន ភ្លាម សូមយល់ចិត្តបងផង កុំយល់ច្រឡំនឹងបងអី ។

សម្ផស្ស សូមក្លាហានឆ្លើយជាចុងក្រោយបំផុត ថាអូនស្រឡាញ់បង បានទេ ?

រង់ចាំចម្លើយរបស់អូនជានិច្ច

ស៊ុម-សម្បត្តិ

## ១៥-លិខិតឆ្លើយតបនឹងលិខិតខាងលើ

ភ្នំពេញ, ថ្ងៃទី ៣១ សីហា ១៩៩៨

**មកដល់សម្បត្តិ**

បងសម្បត្តិ ! បងពុំគួរណាក្តៅចុងច្រមុះ ច្រឡោតខាង តតូងតតាង នឹង អូនភ្លាមៗ សោះ ការដែលអាក់ខានយូរនេះ សូមបងយល់អោយច្បាស់ថា មិន មែនមកពីអូនយល់ថាបងច្រឡើសបើស ច្រឡោងខាម ប៉ោឡែប្រកោ មិន អាចបំពេញចំណុចចិត្តរកសុភមង្គលអោយអូនមិនបាន ដូចពាក្យចោទក្នុង ប្រយោគឃ្លោងឃ្លាទាំងទទឹងទាំងមកកាន់អូននោះឡើយ ។

សម្ផស្ស ដឹងហើយ ! ថាបងជាសុភាពបុរសពិតៗ អាចអោយកញ្ញា

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

ទាំងឡាយមិនខ្វាចញញើតនឹងផ្សងវាសនាលើបងទេ គួរតែប្រថុយផ្ញើណាស់ដែរ...។ ក៏ប៉ុន្តែសូមបងដែលអួតខ្លួនជាអ្នកមានសញ្ញាប័ត្រជាន់ខ្ពស់ផុតមេឃជ្រាបឱ្យច្បាស់ថា សម្ផស្ស ជាកូនចៅខ្មែរ មានមាតាបិតាថែរក្សាព្រឹកល្ងាចបើបងពិតជាកូនប្រុសជាប់សែជាខ្មែរសុទ្ធ១ គួរណាស់ក្រឡេកមើលច្បាប់ក្បួនទំនៀមទំលាប់ខ្មែរខ្លះ១ ផង តើប្រពៃណីខ្មែរ ច្បាប់ស្រុកទេសយ៉ាងម្តេចខ្លះ? ឆ្លើយមកមើល ?

បងសម្បត្តិ ! កុំអាល់យល់ខុសថា សម្ផស្ស ស្រឡាញ់បងដោយសម្លឹងឃើញសន្លឹកសញ្ញាប័ត្រខ្ពង់ខ្ពស់នោះអោយសោះ ខុសហើយ សម្ផស្សស្រឡាញ់ប្រុសម្នាក់មានចិត្តទៀងត្រង់ស្មោះបរិសុទ្ធតែប៉ុណ្ណោះ ទោះបីបងមានសញ្ញាប័ត្រដល់ទៅរាប់រយសន្លឹកខ្ពស់ឧត្តម១ ក៏សម្ផស្សមិនស្រឡាញ់បងដែរ ! បងជាមនុស្ស មិនអាចអោយសម្ផស្សជឿចិត្តបានទេ ! ចិត្តបងជាទេវទត្តឯចំណែកមាត់បងជាទេវតា វាចាបងផ្អែមណាស់ ស្រឡាញ់អូនតែម្នាក់ ស្មោះតែអូនម្នាក់ ប៉ុន្តែចិត្តបងជាព្រានទារីម្នាក់ យកឡាន យកសញ្ញាប័ត្រធ្វើជាអន្ទាក់បំផ្លាញព្រហ្មចារីយ៍ស្រីក្រមុំល្ងង់ខ្លៅអស់ប៉ុន្មាននាក់ហើយ ?

គួរពិចារណាមើលអោយភ្លឺភ្នែកផង ! កុំមកបោកប្រចង់បំផ្លាញរូបសម្ផស្សអោយសោះ កុំច្រឡំថាសម្ផស្សជាស្រីចិញ្ចើមថ្ពល់ មើលត្រកូលអោយច្បាស់ផងមុននឹងនិយាយ ។

សូមបងកុំភ្លេច "មុនហានិយាយរៀបរាប់ ក្រលាស់អណ្តាតអោយបាន

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

មួយរយដងសិន កុំអាងតែអណ្តាតឥតឆ្អឹង តែចេះក្រលាស់បោកបោកប្រាស ល្អតែខាងក្រៅ តែខាងក្នុងវិញដូចជាផ្លែល្វា គេមិនស្តាប់អាប់ប្រាជ្ញាទេបង ! ។

ម្តងនេះអោយអស់សង្ស័យទៅ សម្ផស្សដាច់ខាតមិនស្រឡាញ់បង ទេ១១ ។

ទីបំផុត សម្ផស្ស សុំថ្លែងនូវសេចក្តីត្រេកអរផង ចំពោះជោគវាសនា ដែលបងជាប់សញ្ញាប័ត្រនោះណាស់ ។ សូមបងយកទៅដាក់ដៃនារីណាក្រៅ សម្ផស្សទៅ ។

ជាតិនេះ សម្ផស្សគ្មានកម្មពៀរនឹងបងទេ ១១ ។

ពាក្យគួរពុំសម សូមអភ័យទោស

ឈប់សង្ស័យទៅណា៎

(ហត្ថលេខា)

**ចាន់ សម្ផស្ស**

## ១៦_លិខិតសូមសារភាពពីកំហុសខ្លួន

ក្រោមពន្លឺចង្កៀងដ៏ខ្សោយ អស់សង្ឃឹម យប់ថ្ងៃទី ២ កញ្ញា ១៩៥៨

**អូនសម្ផស្សជាស្រឡាញ់**

អូនសម្ផស្ស ស្ងួនខ្ទឹមចិត្តមាសពុំងារ ពុំគួរណាបងសរសេរសំបុត្រមករំខាន

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

អូនសោះ តែបើបងនៅសម្ងំស្ងៀម អត់ទ្រាំនឹងសរសេរសំបុត្រពុំបាន ត្រូវខ្វាក់ពាក្យពិតមកថ្លែងសារភាពចំពោះអូនអោយបានដឹង ។

សម្ផស្ស ! បណ្ដូលចិត្តបង ! សូមអូនដកលស្មារតីអានសំបុត្រអោយចប់សិន ហ៊ឺ ! អូនអើយ បងខុសហើយបានសរសេរសំបុត្រប្រើពាក្យមិនគប្បីចំពោះអូន ចូរអូនជេរស្ដីតិះដៀលបងឱ្យអស់ចិត្តចុះសមតាមកំហុសរបស់បង បងស្ដាយក្រោយណាស់ បងមិនគួរសេរសេរដូច្នេះសោះ តែមកពីបងស្រឡាញ់អូនពេក ទើបមិនអាចទប់អារម្មណ៍បាន បងពិតជាស្រឡាញ់អូនដោយស្មោះមែន ចិត្តបងមិនមែនជាទេវទត្តនោះទេ ពាក្យពេចន៍ទាំងអស់សុទ្ធជាការពិត វាបានផុសចេញពីដួងចិត្តដ៏បរិសុទ្ធរបស់បងពិតៗ ។ សូមអូនអភ័យទោសដល់បងផង សូមអោយបងបានជួបអូនជាលើកចុងក្រោយផង ។ ល្ងាចនេះបងសូមជួបអូននៅគេហដ្ឋានអូននៅវេលា៦គត់កុំខានណាអូន ដើម្បីចូលខ្លួនអោយអូនស្ដីបន្ទោសតាមកំហឹងអូន ។

អូនសម្ផស្ស ! ឬមួយក៏អូនមិនចង់អោយបងជាន់កាំជណ្ដើរអូនទេ ។ កំហុសទាំងអម្បាលមាណ បងទទួលខុសទាំងអស់ ។

បងសង្ឃឹមថា អូនអនុញ្ញាតអោយបងជួបមិនខាន ។

ឈប់ខឹងបងទៅព្រលឹងមាសបង

ស៊ុម~ សម្បត្តិ

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

## ១៧. លិខិតជាចំណងដៃ ក្នុងពេលរៀបអាពាហ៍ពិពាហ៍ អតីតសង្សារ

ក្នុងខ្ទមកំសត់ក្រោមម្លប់ឈើ, ថ្ងៃទី ១២ កញ្ញា ២០០០

**មកអូនចរិយារបស់បង**

ចរិយាអូន បងសែនស្ដាយណាស់ ដោយកាលៈទេសៈមិនផ្ដល់អោយបងឈានដើរចូលរួមជាភ្ញៀវពេញកិត្តិយស ក្នុងមហាពិធីលៀងភោជនាហារអាពាហ៍ពិពាហ៍របស់អូនបានឡើយ ។

បងទទួលត្រេកអរណាស់ ដែលអូននៅនឹកឃើញ ហើយបានអញ្ជើញបងឱ្យទៅចូលរួមក្នុងពិធីមង្គលការរបស់អូន ។

បានសេចក្ដីថា អូនមិនទាន់បំភ្លេចឈ្មោះបង ក្នុងស្រទាប់ចិត្តដ៏បរិសុទ្ធរបស់អូនដែរ ។ ប៉ុន្តែអូនអើយ បងស្ដាយណាស់ បងមិនអាចឈានជើងបោះជំហានចូលក្នុងពិធីនេះបានទេ ។

ចរិយាអូន សូមអូនអភ័យទោសអោយបងផង បងសុំថ្លែងទឹកចិត្ត និងមនោសញ្ចេតនាដ៏ជ្រាលជ្រៅ នឹងសែនបរិសុទ្ធមួយហ្នឹង សូមកួចចំណងដៃប្រសិទ្ធិពរជ័យខ្លះៗ ដែលហូរផុសចេញពីផ្ចិតចិត្តកណ្ដាលបេះដូងបងសុទ្ធសាធ ។

ចរិយាអូន បងក្រណាស់ គ្មានអ្វីដ៏មានតម្លៃចងដៃអូនទេ មានតែសៀវភៅប្រលោមលោក ៥ ក្បាល "ភ្លេងការប្រហារដួងចិត្ត, សប្បាយចិត្ត

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

ណាស់ម៉ែអោយមានប្ដី. សត្រូវ វាសនាស្នេហាំរលត់. ស្នេហាផ្ដាំចាស់. បាបមិនបានផ្អាបមាត់" និងសៀវភៅ"ភារកិច្ចស្ត្រី" តែប៉ុណ្ណោះ ដែលជាស្នាដៃការនិពន្ធរបស់បង ។ បងសូមផ្ញើអូនមកនូវខ្សែករបន្ទោងបេះដូង ដែលអូនបានបំពាក់ឱ្យបងក្រោមដំបូងខ្ទមជរាដ៏កំសត់ កាលយើងចាប់បណ្ដុះផ្ដាលស្នេហាទុកជាអនុស្សាវរីយ៍ ។

ពីថ្ងៃនេះ អូនត្រូវផ្លាស់វីយ ផ្លាស់គំនិត ជាស្ត្រីមេផ្ទះដ៏ចំណាន ជាមាតានៃបុត្រ ជាទ្រព្យគាប់ចិត្តរបស់ស្វាមីអូន ។

បងសូមបួងសួងគុណបុណ្យវត្ថុសក្តិសិទ្ធិក្នុងលោក និងព្រះរតនៈត្រៃកែវទាំងបី ព្រមទាំងពុទ្ធពរទាំង៤ប្រការ ចូរកើតមានដល់អូន និងសូមឱ្យស្នេហាស្វាមីភរិយាអូនប្រកបដោយសុភមង្គល ។

អូនកុំបារម្ភដល់បងអោយសោះ ព្រោះបងរស់នៅយ៉ាងសុខសាន្តណាស់ក្រោមដំបូលខ្ទមកំសត់ក្នុងព្រៃ ។ ពេលយប់សប្បាយ ស្ដាប់ដង្ហើមរាត្រីស្ដាប់សូរតន្ត្រី នៃធម្មជាតិស្ដាប់បក្សាបក្សី ដំរី ខ្លា ម្រឹគី ម្រឹគា ចចក ស្វាន ស្វាទន្សាយ ឈ្លូស រមាំង.... បោលខ្ទោល១ ប្រឹបប្រោក បញ្ចេញសំលេងសែនពិរោះ ដូចជាចម្រៀងតូរ្យតន្ត្រី ។

ចុងបញ្ចប់នៃដំណក់ទឹកប៉ាកានេះ សូមអូនទទួលនូវសេចក្ដីរាប់អានដូចដើម និងនឹករលឹកធម្មតាអំពីបង ។

យុវជនអភ័ព្វស្នេហ៍ម្នាក់

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

# II-លិខិតសំរាប់កិច្ចការផ្សេងៗ

លិខិតបែបនេះ គេសរសេរមិនឱ្យវែងពេកទេជាការឥតប្រយោជន៍ ។ គេសរសេរតែពាក្យណាសំខាន់ៗ មានប្រយោជន៍តែប៉ុណ្ណោះ ។

ប៉ុន្តែក្នុងការសរសេរលិខិតនេះត្រូវពិនិត្យបន្តិចដែរ ហើយកុំភ្លេចបញ្ចូលពាក្យគួរសមបន្តិចនៅទីបញ្ចប់នៃសំបុត្រ ។

## ១_ លិខិតអញ្ជើញ

### ក_លិខិតអញ្ជើញមិត្តចូលរួមដំណើរទេសចរណ៍

លេខ ១៦៧, មហាវិថីម៉ៅស៊ីងទុង ភ្នំពេញ

ថ្ងៃទី ៣០ វិច្ឆិកា ១៩៩៩

មកដល់លោកសុជាតិជាទីគោរព

យើងខ្ញុំសូមផ្ញើជូនដំណឹងល្អមួយចំពោះលោក ចាប់ពីថ្ងៃព្រហស្បតិ៍ ទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៩៩ ខាងមុខនេះ ពីធីទទួលសហសវត្សថ្មី នឹងប្រារព្ធឡើងនៅមុខប្រាសាទអង្គរវត្ត ។

យើងខ្ញុំសូមអញ្ជើញលោកចូលរួមក្នុងពិធីអបអរទទួលសហសវត្សថ្មី ដែលរៀបឡើងដោយក្រសួងទេសចរណ៍និងរាជរដ្ឋាភិបាលកម្ពុជា នៅប្រាសាទអង្គរវត្តដ៏ល្បីល្បាញរបស់យើង ។

យើងខ្ញុំជឿថា លោកនឹងអញ្ជើញចូលរួមក្នុងពីធីអបអរទទួលសហ-

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

សវត្សថ្មីនេះនៅថ្ងៃទី៣០-៣១ ខែ ធ្នូ ឆ្នាំ ១៩៩៩ ជាមិនខាន ។

សេចក្តីស្រឡាញ់ពីយើងខ្ញុំ

**គង់ ឌីណា**

## ខ_លិខិតអញ្ជើញចូលរួមពិធីសម្ពោធ

លេខ ២០, វិថីប៉ាស្ទ័រ ក្រុងភ្នំពេញ

ភ្នំពេញ, ថ្ងៃទី ១២ កុម្ភៈ ១៩៩៩

មកដល់លោក ចន្ថា ជាទីគោរព

យើងខ្ញុំសូមផ្ញើជូនដំណឹងល្អមួយចំពោះលោក ចាប់ពីថ្ងៃពុធ ទី ២០ សីហាសប្តាហ៍ខាងមុខនេះ Mc Intire នឹងចាប់ផ្តើមផ្សាយអត្ថបទ ៥០ ក្នុង ១ សប្តាហ៍ ដើម្បីសង្ខេបសៀវភៅប្រលោមលោកថ្មីដ៏ល្បីល្បាញឈ្មោះបំផុត ។

យើងខ្ញុំសូមអញ្ជើញលោកចូលរួម ..... ប្រលោមលោកថ្មីដ៏គួរឱ្យចាប់ចិត្តរបស់អ្នកនិពន្ធ ហុយ វាសនា និងត្រូវបានឧទ្ទេសនាមនៅថ្ងៃពុធខាងមុខនេះ ដោយនាងកញ្ញាណារី វាក៏ជាប្រលោមលោក ដ៏ល្បីលាញមួយដែលមានឥទ្ធិពល និងត្រូវបានប្រជាជននៅកម្ពុជាទទួលស្គាល់ ។

ការឧទ្ទេសនាមរិះគន់ក៏ដូចជាបរិសណ្ឋារកិច្ចនឹងត្រូវបានប្រព្រឹត្តទៅនៅបន្ទប់ទទួលភ្ញៀវដែលមានម៉ាស៊ីនត្រជាក់នៅជាន់ទី ៣ នៃសណ្ឋាគារ Sunway ។ កម្មវិធីនឹងចាប់ផ្តើមនៅវេលាម៉ោង ២.១៥ នៅថ្ងៃពុធ យើងខ្ញុំនឹងជូនដំណឹង

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

ដល់អ្នកសង្ខេបឧទ្ទេសនាមសៀវភៅហើយរឿងប្រលោមលោកនឹងឧទ្ទេសនាម នៅសប្តាហ៍ក្រោយ ។

យើងខ្ញុំជឿថា លោកនឹងអញ្ជើញចូលរួមកម្មវិធីជួបជុំនៅថ្ងៃពុធ សប្តាហ៍ខាងមុខនេះជាមិនខាន ដោយហេតុថា យើងខ្ញុំអញ្ជើញតែអ្នកមានការិតយល់ដឹងនិងបទពិសោធក្នុងការសិល្បៈសង្ខេបឧទ្ទេសនាមសៀវភៅប៉ុណ្ណោះ ។ សង្ឃឹមថាលោកនឹងឆ្លៀតពេលវេលាមកចូលរួមជាមួយនៅថ្ងៃពុធវេលាម៉ោង ២.១៥ ខាងមុខនេះជាមិនខាន ។

ដោយក្តីរាប់អានពីខ្ញុំ

**ម៉ី សុខរ័ត្ន**

## គ. លិខិតអញ្ជើញមិត្តឱ្យមកជួប

ផ្ទះលេខ ១០ វិថីប៉ូលេអុង ភ្នំពេញ

ថ្ងៃទី ៣១ មិនា ឆ្នាំ ១៩៩៩

ប្អូនវិសាលជាទីស្រឡាញ់

ខ្ញុំទើបនឹងបានដំណឹងថា ប្អូនបានទៅរកខ្ញុំព្រឹកម្សិលមិញក្រោយ ពេលដែលខ្ញុំចេញផុតបន្តិច ។ ខ្ញុំមានសេចក្តីស្តាយជាក្រៃលែងដោយមិនបាននៅផ្ទះមិនបានជួបគ្នា ព្រោះខ្ញុំបានដំណឹងថ្មីមួយដ៏ល្អ ដើម្បីយកមកថ្លែងប្រាប់ ។ គឺបំណងរបស់ប្អូនទាំងប៉ុន្មាន ខ្ញុំស្វែងរកឱ្យបានសំរេចហើយៗ ពិសេសជាងនោះ

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

ទៅទៀតផង ។ ដូច្នេះចូរប្អូនទៅជួបនឹងខ្ញុំយ៉ាងរួសរាន់ ខ្ញុំនឹងនិយាយប្រាប់ភិនភាគទាំងឡាយនោះ ។ ក្នុងពេលនេះ ប្អូនត្រូវសង្ឃឹមទុកថា កិច្ចការទាំងនោះបានសំរេចលទ្ធផលរួចស្រេចហើយ ។

សង្ឃឹមថានឹងបានជួបប្អូនពិតប្រាកដ ។

ស៊ុម សម្បត្តិ

## ឃ. លិខិតអញ្ជើញមិត្ត មកលេងទីក្រុង

លេខ ៣៧. វិថីព្រះត្រពាំង ភ្នំពេញ

ថ្ងៃទី ១ កក្កដា ១៩៩៩

**យុទ្ធារះ**ជាទីរាប់អាន

តាំងពីខ្ញុំបានជួបមិត្តនៅឯក្រុងវៀងច័ន្ទ មកទល់នឹងថ្ងៃនេះ អស់រយៈពេលជាងមួយឆ្នាំហើយ ។

ក្នុងចិរវេលា ៣ ថ្ងៃ ដែលខ្ញុំបានស្នាក់នៅជាមួយនឹងមិត្តនោះ ជាឱកាសសប្បាយមួយរកទីបំផុតគ្មាន !

តើក្នុងឆ្នាំនេះ មិត្តមានបំណងចង់មកលេងជាមួយនឹងខ្ញុំរាជធានីភ្នំពេញបានមួយសប្តាហ៍ដែរទេ? ប្រហែលជាលើកដំបូងបង្អស់របស់មិត្តការឈានជើងជាន់ដីខ្មែរ ហើយការពិសោធន៍ទៀតនិងនៅថ្មីថ្មោងថែមទាំងប្លែកភ្នែកចំពោះមិត្តយ៉ាងពិតប្រាកដ ។

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

បើសិនជាមិត្តយល់ព្រម អញ្ជើញទៅលេងនឹងខ្ញុំសូមតបសំបុត្រមកឱ្យខ្ញុំបានដឹងថ្ងៃខែដែលមិត្តអញ្ជើញជាមុន. ដើម្បីជាការងាយដល់ខ្ញុំក្នុងការរៀបចំទទួលដំណើររបស់មិត្ត ។

ខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងកក់ក្តៅថា មិត្តនឹងឆ្លៀតឱកាសមកលេងមិនខាន ដើម្បីឱ្យខ្ញុំបានរិតចំណងមេត្រីភាពបានជិតស្និទ្ធថែមទៀត ។

សូមមិត្តទទួលនូវសេចក្តីរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ ។

**នាក់ សំអឿន**

## ២. លិខិតយល់ព្រម

ផ្ទះលេខ ២៤E$_0$ ផ្លូវលេខ ២៣៨ ភ្នំពេញ

ថ្ងៃទី ១០ ធ្នូ ១៩៩៩

ចំពោះលោក**ឱណា** ជាទីគោរព

សូមអរគុណចំពោះការអញ្ជើញរបស់បង ខ្ញុំនឹងសប្បាយរីករាយណាស់ក្នុងការទៅចូលរួមក្នុងពិធីអបអរទទួលសហសវត្សថ្មី នៅថ្ងៃទី ៣០-៣១ ខែធ្នូ ឆ្នាំ ១៩៩៩ នេះ នៅប្រាសាទអង្គរវត្ត ខេត្តសៀមរាបនេះ ។

អរគុណជាពន្លឹកចំពោះ ទឹកចិត្តរបស់បងដែលបានអញ្ជើញខ្ញុំ ។

ដោយក្តីស្រឡាញ់ពីខ្ញុំ

**សុជាតិ**

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

# ៣. លិខិតបដិសេធ

## ក. បដិសេធមិនបានរួចដំណើរទេសចរណ៍

ផ្ទះលេខ ២៤E₀ ផ្លូវលេខ ២៣៨ ភ្នំពេញ
ថ្ងៃទី ៥ ធ្នូ ១៩៩៩

ចំពោះលោក**ឌីណា**

ខ្ញុំសែនត្រេកអរនិងមានកិត្តិយសណាស់ ដោយបានការអញ្ជើញឱ្យចូលរួមក្នុងពិធីអបអរទទួលសហសវត្សថ្មី ដែលជិតនឹងរៀបចំឡើងនៅមុខប្រាសាទអង្គរវត្ត ចាប់ពីថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៩៩ ដល់ថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០០ ។

ជាបឋមខ្ញុំសូមអភ័យទោសដោយយឺតយ៉ាវក្នុងការឆ្លើយតបសំបុត្ររបស់លោក ព្រោះខ្ញុំត្រូវជាប់បេសកកម្មនៅឯបរទេសនាចុងឆ្នាំនេះ ។

ខ្ញុំស្ដាយណាស់ដោយត្រូវជូនដំណឹងដល់លោកថា ខ្ញុំមិនអាចចូលរួមក្នុងពីធិអបអរទទួលឆ្នាំសហសវត្សថ្មីនេះជាមួយនឹងលោក ។

ជាថ្មីម្ដងទៀតខ្ញុំសូមសំដែងអំណរអរគុណចំពោះលោកដែលបានអញ្ជើញខ្ញុំ ហើយសូមឱ្យដំណើរកំសាន្តរបស់ប្រកបដោយសុវត្ថិភាព ។

ដោយក្ដីរាប់អានអំពី

**សុជាតិ**

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

## ៦. លិខិតប្រកែកមិនទៅជួប

លេខ ១០, វិថីប៊ូលេអុង ភ្នំពេញ

ថ្ងៃទី ៣១ មករា ១៩៩៩

បងសម្បត្តិ

ខ្ញុំមានសេចក្ដីសោកស្ដាយណាស់មិនបានមកជួបនឹងបងទេ ដោយហេតុខ្ញុំមានជម្ងឺរោគាក្នុងខ្លួន លោកប៉ាមិនឲខ្ញុំចេញចោលបន្ទប់ដេកក្នុងរវាងពីរ-បីថ្ងៃ បានឡើយ ។

សូមបងមេត្តា អញ្ជើញទៅលេងនឹងខ្ញុំវិញ ។ ខ្ញុំនឹងលោកប៉ាខ្ញុំចង់ជួបនឹងបងណាស់ ។

សូមគោរពមិត្តក្នុងភាពដ៏ខ្ពង់ខ្ពស់

**ឡុយ វិសាល**

## ៤. លិខិតសូមអភ័យទោស

ភ្នំពេញ, ថ្ងៃទី ៥ មករា ១៩៩៩

គោរពជូនលោក**ម៉ុនឆៀន**

ខ្ញុំសប្បាយរីករាយណាស់ ដោយបានទទួលសំបុត្ររបស់លោកចុះថ្ងៃទី ១០ វិច្ឆិការ ឆ្នាំ ១៩៩៩ នេះពិតជាកិត្តិយស ដ៏ខ្ពង់ខ្ពស់ដោយបានសហការណ៏

www.budinst.gov.kh www.elibraryofcambodia.org

ជាមួយលោកខ្ញុំនឹងពិនិត្យឡើងវិញនូវសំណុំរឿង របស់ខ្ញុំក្នុងរយៈពេលប៉ុន្មានថ្ងៃខាងមុខនេះ ហើយនឹងរើសយកនូវឧទាហរណ៍ដែលបានប្រកាសផ្សាយពីប្រព្រឹត្តការណ៍ពិសេសៗ ដែលខ្ញុំគិតថានឹងមានប្រយោជន៍ចំពោះលោក ។

ឥឡូវនេះ ខ្ញុំកំពុងរួសរាន់សរសេររបាយការណ៍ ដើម្បីជំរាបជូនអង្គប្រជុំកម្មាភិបាលនៅក្រសួងខ្ញុំនាថ្ងៃខានស្អែក អាស្រ័យហេតុនេះសូមលោក មេត្តាបង្អែរបង្អង់បន្តិចទៀត ដើម្បីខ្ញុំប្រមែប្រមូល ឯកសារដែលលោកផ្តោតការយកចិត្តទុកដាក់ ។

គំរោងការណ៍របស់លោកមើលទៅហាក់ទៅដូចជាមានតម្លៃណាស់ ខ្ញុំជូនពរលោកឱ្យទទួលបានជោគជ័យ ។

ដោយក្តីគោរពពីខ្ញុំ

**ឆា ខណ្ឌពិសិដ្ឋ**

❋❋❋❋❋

ផ្ទះលេខ ២៤ A<sub></sub>E0 ផ្លូវលេខ ៣២៨. ចំការមន

ថ្ងៃទី ២០ តុលា ១៩៩៩

**សំឡាញ់ !**

ខ្ញុំមានបំណងចង់មកជួបផ្ទាល់នឹងសំឡាញ់ ដើម្បីសូមលាគ្នាមុនពេលសំឡាញ់ធ្វើដំណើរចេញទៅសៀមរាប ប៉ុន្តែដោយមានទូរលេខពីក្រុមហ៊ុន

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

អោយខ្ញុំទៅជាប្រញាប់ ខ្ញុំមិនអាចរកឱកាសមកជួបនឹងសំឡាញ់មុននឹងឡើងយន្តហោះបានឡើយ ។

សូមសំឡាញ់ជឿជាក់ថា: ខ្ញុំមានសេចក្ដីសោកស្ដាយពន់ពេកណាស់ ហើយសូមអភ័យទោសដល់ខ្ញុំផង ។

ខ្ញុំមានសេចក្ដីសង្ឃឹមយ៉ាងកក់ក្ដៅថា នឹងបានជួបមុខគ្នានៅពេលក្រោយទៀត ។ សូមសំឡាញ់ទទួលនូវសេចក្ដីគោរពក្នុងមិត្តភាពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ ។

ដោយក្ដីស្រឡាញ់ពីខ្ញុំ

**វិចិត្រ ទេវី**

## ៥_លិខិតសុំជួលបន្ទប់សំណាក់ណាមួយ

ភ្នំពេញ, ថ្ងៃទី ៥ កញ្ញា ១៩៩៩

ជំរាបមកលោកនាយកសណ្ឋាគារឆ្នេរទន្លេ

នៅពេលបុណ្យភ្ជុំបិណ្ឌថ្ងៃទី៩កញ្ញាខាងមុខនេះ ខ្ញុំនឹងនាំគ្រួសារទៅលេងក្រុងព្រះសីហនុ ដើម្បីយកខ្យល់អាកាសបរិសុទ្ធ ។ ហេតុនេះ សូមលោកមេត្តាលៃលកទុកបន្ទប់មួយសំរាប់ខ្លួនខ្ញុំ; ប្រពន្ធខ្ញុំកូនស្រីខ្ញុំអាយុ ១២ ឆ្នាំម្នាក់ នឹង កូនប្រុសតូចម្នាក់ទៀត ។ បន្ទាប់នោះ សូមយកបន្ទប់ណាដែលនៅខាងគេ ហើយមានទ្វារ ឬបង្អួចបែរឆ្ពោះទៅមាត់សមុទ្រ ដើម្បីឱ្យទទួលខ្យល់សមុទ្រ បានដោយស្រួលហើយខ្ញុំត្រូវនៅបរិភោគអាហារក្នុង



www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

ភោជនីយដ្ឋានលោកទៀត ។

ខ្ញុំនឹងនឹងធ្វើដំណើរទៅដល់ក្រុងព្រះសីហនុនៅថ្ងៃទី ០៩ កញ្ញា ប្រហែលម៉ោង ១១ ព្រឹក ។

សូមលោកទទួលនូវមេត្រីភាគអំពីខ្ញុំ

ឡុង-សុជាតិ

ក្រសួងទេសចរណ៍,ភ្នំពេញ

## ៦_លិខិតសុំធ្វើការក្នុងគ្រឹះស្ថានជំនួញណាមួយ

ភ្នំពេញ, ថ្ងៃទី ២០ សីហា ១៩៩៩

សូមជំរាបមកលោកចាងហ្វាងនៃសណ្ឋាគារ

Le Royal

សូមជ្រាប,

ខ្ញុំឈ្មោះនាក់ សំអឿន អាយុ ២០ ឆ្នាំ ជាតិខ្មែរជាអតីតសិស្សនៃមហាវិទ្យាល័យពាណិជ្ជសាស្ត្រ. ទីលំនៅសព្វថ្ងៃផ្ទះលេខ ១៧០B ផ្លូវលេខ ១៦៧ សង្កាត់ទួលទំពូង II ក្រុងភ្នំពេញ ។

ដោយឃើញសេចក្ដីផ្សាយរបស់លោក ក្នុងសារពតិមានអំពាវនាវរកអ្នកគ្រប់គ្រងបុគ្គលិកម្នាក់. ខ្ញុំសូមធ្វើលិខិតនេះនាំចូលមកសុំឱ្យលោក

www.budinst.gov.kh www.elibraryofcambodia.org

មេត្តា អនុញ្ញាតឱ្យខ្ញុំចូលធ្វើការក្នុងដំណែងនោះតទៅ ។

សូមលោកទទួលយកនូវគារវភាពយ៉ាងគោរព ដ៏ជ្រាលជ្រៅរបស់ខ្ញុំ ។

(ហត្ថលេខា)

## ៧_លិខិតឆ្លើយតបលិខិតខាងលើ

ភ្នំពេញ, ថ្ងៃទី ២២ សីហា ១៩៩៩

ជំរាបលោក នាក់-សុំអឿន

ផ្ទះលេខ ១៧០B ផ្លូវលេខ ១៦៧ ភ្នំពេញ,

តបនឹងសំបុត្រសុំធ្វើការរបស់លោកចុះថ្ងៃទី ២០-០៨-៩៩ ដែលបញ្ជូនមកដល់ខ្ញុំពីម្សិលមិញ ។ ឥឡូវនេះ ខ្ញុំមានសេចក្ដីរីករាយនឹងអញ្ជើញលោកមកជួបនឹងខ្ញុំ ដើម្បីសន្ទនាការផ្សេងៗ នៅសណ្ឋាគាររបស់ខ្ញុំ នៅពេលដែលបើកទ្វារធ្វើការ ហើយការនេះត្រូវប្រញាប់ក្នុងពេលឆាប់ៗនេះផង ។

សូមទទួលសេចក្ដីរាប់អានអំពីខ្ញុំ ។

ចាងហ្វាងនៃសណ្ឋាគារ

ឡី រ៉ូយាល់

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

## ៨_លិខិតហៅជាងមកជួសជុលផ្ទះ

ជំរាបមកលោកសហគ្រិន វឌ្ឍនា

ភ្នំពេញ.

សូមលោកមេត្តាចាត់ឱ្យជាងឈើម្នាក់ ក្នុងសហគ្រាសរបស់លោក មកកាន់ផ្ទះខ្ញុំលេខ ៦៤Z មហាវិថីមុនីវង្ស ដើម្បីពិគ្រោះក្នុងការជួសជុល ទ្វារនឹងបង្អួចផ្ទះខ្ញុំនៅជាន់ខាងលើ ។ សូមលោកចាត់ឱ្យមកក្នុងវេលាល្ងាច នេះកុំខាន ព្រោះខ្ញុំនៅចាំជួប ។ ទ្វារនឹងបង្អួចនេះ ខ្ញុំចង់ដោះចោលគ្រឿង ចាស់ នឹងត្រូវធ្វើបែបថ្មីដាក់ជំនួសវិញ ដូច្នេះសូមលោកឱ្យទាំងគំរូ ហាត់ដោ ទ្វារបង្អួចបែបសម័យ នឹងប្រាប់តម្លៃឈ្នួលធ្វើឬទាំងថ្លៃឈើមក ជាមួយផង ។

ខ្ញុំសូមថ្លែងអំណរគុណចំពោះលោកជាមុន ។

ម្ចាស់ផ្ទះ

(ហត្ថលេខា)

**ចាន់_ចំរើន**

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

# III-លិខិតជូនពរនិងសំដែងទឹកចិត្ត

លិខិតនេះ មិនចាំបាចសរសេរវែងពេកទេ គឺគេសរសេរខ្លីៗ បំផុត គឺគ្រាន់តែថ្លែងជាពាក្យបួនដប់ម៉ាត់ដិណាងទឹកចិត្តរបស់យើងតែប៉ុណ្ណោះ ។ ឧបមា មិត្តយើងទើបតែប្រឡងជាប់ ហើយយើងចង់សរសេរលិខិតមួយច្បាប់ដើម្បីសំដែងសេចក្តីរីករាយចំពោះមិត្តយើងនោះ តែប៉ុន្មានម៉ាត់ជំនួសខ្លួនយើងដែលមិនបានទៅដោយផ្ទាល់ ។ ក្រៅពីនេះ ដូចជាជូនពរក្នុងពិធីបុណ្យខួបកំណើត ចូលឆ្នាំថ្មី ពិធីរៀបអាពាហ៍ពិពាហ៍ និងពេលទទួលយសសក្តិដ៏ពេញចិត្ត ឬពេលដែលបានទទួលរង្វាន់អ្វីមួយដ៏ប្រសើរនោះ ក៏ចាត់ទុកជាពេលដែលត្រូវសរសេរលិខិតជូនពរនិងសម្តែងទឹកចិត្តទៅជួយអបអរសាទរដល់មិត្រដែលជាមិត្តយើងនោះដែរ ។

## ១_លិខិតជូនពរ

### ក_ជូនពរមិត្ត ក្នុងឱកាសឡើងឋានៈថ្មី

មកដល់ មូនីថា

ក្នុងឱកាស ដែលមិត្តត្រូវបានជ្រើសតាំងឱ្យកាន់កាប់មុខតំណែងប្រធានលេខាធិការរបស់ទីចាត់ការ ខ្ញុំសូមផ្ញើជូននូវប្រសិទ្ធិពរជ័យមហាប្រសើរដ៏កក់ក្តៅបំផុតចំពោះមិត្តនិងគ្រួសារ ។ គ្នាដឹងថាមិត្តនិងគ្រួសារមិត្ត នឹងសប្បាយរីករាយយ៉ាងណានោះ ។

សូមមិត្តចាត់ទុកការតម្លើងឋានៈនេះ ជារង្វាន់ចំពោះការខិតខំប្រឹងប្រែង និងមិនចេះនឿយហត់ក្នុងរយៈពេលជាច្រើនឆ្នាំរបស់មិត្ត ជំនួសមុខឱ្យក្រុមហ៊ុននោះ ។

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

សូមជូនពរមិត្តជួបនឹងកំពូលវាសនាល្អ ក្នុងភារកិច្ចថ្មីនេះរបស់មិត្ត ។

សេចក្តីស្រឡាញ់រាប់អាន

ប៉ាវ សុវណ្ណារី

## ខ_លិខិតជូនពរថ្ងៃបុណ្យណូអែល

មកដល់លីណា

ថ្ងៃបុណ្យខួបកំណើតព្រះយេស៊ូ "Christmas" បានកំណត់សម្គាល់នូវដំណាក់កាលចុងក្រោយនៃដំណើរឆ្នាំ ១៩៩៩ ជិតដល់ទីបញ្ចប់ហើយ ។ ចំពោះយើងផ្លូវដែលយើងបានឆ្លងកាត់នាឆ្នាំកន្លងមក ជាវិថីនៃជីវិតដ៏រាបស្មើល្អ និងចំរើនជឿនលឿនទៅមុខ ។

ពេលដែលលោកតាពេលវេលាបើកភ្លើងខៀវមានន័យ យើង "ឈានឆ្ពោះទៅ" ឆ្នាំ ២០០០ ហើយយើងនិងរួមគ្នាឈានទៅដណ្តើមស្នាដៃដ៏ធំធេងជាងនេះទៅទៀត ។

គ្នាសង្ឃឹមដោយស្មោះថា ឯងនឹងរកឃើញនូវមាគ៌ា ដែលពោរពេញទៅដោយសុភមង្គលនិងសុខភាពជាមួយនឹងពេលវេលាដែលកន្លងផុតទៅនិងមិត្តកាន់តែខិតចូល ទៅជិតទីដៅ ។

ដោយសេចក្តីស្រឡាញ់ពីគ្នា

**ជុំ បុប្ផារត្ន**

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

## គ-សិស្សជូនពរដល់គ្រូក្នុងឱកាសចូលឆ្នាំ

សូមក្រាបប្រណិប័តន៍ចូលមកអ្នកគ្រូ

សូមទានជ្រាប !

ឆ្នាំនេះ ខ្ញុំបាទសោកស្ដាយជាទីបំផុត ដោយមិនបានមកជូននូវសព្ទ-សាធុកាពរជ័យដោយផ្ទាល់ចំពោះអ្នកគ្រូ ខ្ញុំបាទសូមបួងសួង ប្រសិទ្ធិពីចម្ងាយ ក្នុងឱកាសឆ្នាំថ្មីនេះ សូមឱ្យអ្នកគ្រូ ព្រមទាំងគ្រួសារ បានជួបប្រទះតែនឹងជោគជ័យសិរីមង្គល នឹងសេចក្ដីសុខ សេចក្ដីចំរើនគ្រប់កាលកុំបីលស់ខានឡើយ ។

ដោយសេចក្ដីគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ.

**ចេវា វត្ថ្ម**

## ឃ-លិខិតជូនពរសង្សារក្នុងថ្ងៃចូលឆ្នាំថ្មី

ក្រោមជំនោររាត្រីដ៏ត្រជាក់ ភ្នំពេញ. ថ្ងៃទី ១៣ មេសា ១៩៩៩

អូន **លក្ខិណា** មាសបង

ព្រះអាទិត្យ ព្រះចន្ទ្ររះប្រដេញគ្នា-ម៉េប១ បាន៣៦៥ថ្ងៃ សន្ទឹកប្រតិទិនឆ្នាំថ្មី បានបកប្រែថ្មីទែង ព្យួរនៅជញ្ជាំងប្រកបដោយរូបភាពដ៏ស្រស់ ។

ថ្ងៃទី ១៣ មេសា ឆ្នាំថ្មី ទេវតាថ្មីបានយាងមកដល់ហើយ ថ្ងៃនេះជំនោរឆ្នាំថ្មីបក់ត្រសៀក១ សែនត្រជាក់មនោរម្យ ជ្រាបដល់ទងដង្ហើមបេះដូង ។

ពិតមែនតែឆ្នាំចាស់រលាយវិនាសហើយថ្មី១ នេះក្ដី តែសេចក្ដីស្នេហាចិត្តមួយ បេះដូងមួយរបស់យើង នៅរឹងប៉ឹងជាងដែកថែប ដែលគេលត់រាប់ពាន់

www.budinst.gov.kh www.elibraryofcambodia.org

ដងទៅទៀត រឹងមាំដូចថ្មគជសារ មិនងាយរលាយផ្លាស់ៗ ទេ យើងបានរក្សា ខ្ជាប់ខ្ជួនជានិច្ច បងនឹកមកអូនគ្រប់វិនាទី គ្រប់ដង្ហើមចេញចូលរបស់បង ។

**លក្ខិណា** កំពូលស្នេហ៍បង ! ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី បងសូមអធិដ្ឋានបួងសួងដល់គុណព្រះរតនត្រៃ ព្រមទាំងទេវតាឆ្នាំថ្មី សូមប្រសិទ្ធពរជូនអូន និងគ្រួសារអូន ឱ្យរីងរឹតតែប្រកបនូវពុទ្ធពរទាំង៥ប្រការ មានសិរីសួស្តី លើសអំពីឆ្នាំមុនទៅទៀត និងសូមឱ្យស្នេហ៍របស់យើងឋិតថេរជាអមតៈ ។

សូមទទួលសេចក្ដីនឹករលឹកដោយស្មោះពីបង

បងជារបស់អូនតែម្នាក់

**នាគ់ សំអឿន**

## ១_លិខិតផ្ញើជូនពរមិត្តក្នុងពេលរៀបអាពាហ៍ពិពាហ៍

ភ្នំពេញ, ថ្ងៃទី ២៣ កញ្ញា ១៩៩៩

មកដល់**មូនីតា**

ថ្ងៃនេះជាថ្ងៃប្រកបដោយនក្ខត្តឫក្សដ៏ប្រសើរ ដែលត្រូវរៀបពិធីអាពាហ៍ពិពាហ៍របស់សំឡាញ់ ។ ខ្ញុំគ្មានអ្វីជាបណ្ណាការជាវិសេសវិសាលផ្ញើមកជូនមូនីតាទេ មានតែពាក្យប៉ុន្មានម៉ាត់នេះ គ្រាន់ជាគ្រឿងដៅភ្ជាប់នឹងដួងចិត្តមិត្តតទៅអនាគត ។ ខ្ញុំសូមអញ្ជើញពពួកទេវតាទាំងឡាយ សុំឱ្យលោកជួយប្រទានពរជូនដល់សំឡាញ់ ឱ្យបានប្រទះតែនឹងរស្មីពណ្ណរាយនៃសុភមង្គលក្នុងគ្រួសារ ព្រមទាំងសេចក្ដីក្សេមក្សាន្តភិរម្យ ដែលប្រកបដោយធាតុត្រជាក់ក្រៃដូចជាទឹកអនោតស្រះ នៃស្ថានសួគ៌ ។

ដោយចិត្តស្មោះអស់ពីដួងចិត្ត.

ស៊ុម ចរិយា

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

បណ្ណាល័យ
LIBRARY

## ២. លិខិតសំដែងទឹកចិត្ត

### ក. លិខិតសម្ដែងសេចក្ដីរីករាយចំពោះមិត្តដែលទើបបានបុត្រ

ភ្នំពេញ, ថ្ងៃទី ១២ មិនា ១៩៩៩

មកដល់មិត្តជាទីស្រឡាញ់

ខ្ញុំទើបបានទទួលដំណឹងមួយគួររីករាយជាបំផុតអំពីមិត្ត គឺមិត្តទើបបានទារកមួយជាទីស្រឡាញ់ ។

ខ្ញុំព្រមទាំងគ្រួសារ សូមជូនជាប់មកជាមួយនូវពរសព្ទសាធុការដែលជាតំណាងរូបខ្ញុំផ្ញើមកឱ្យទារករបស់សំឡាញ់ សុំឱ្យមានអាយុយឺនយូរ នឹងប្រកបដោយសុខភាពបរិបូណ៌ ។ តទៅទៀត សូមឱ្យក្មួយប្រុសនេះ មានប្រាជ្ញាមុះមុតក្លៀវក្លា ឱ្យបានជាអ្នករក្សាវង្សត្រកូលនឹងជួយជ្រោមជ្រែងប្រទេសជាតិដែលកំពុងត្រូវការរកកុលបុត្រប្រកបដោយចំណេះវិជ្ជាជ្រៅជ្រះ ។

ពីសំឡាញ់របស់មិត្រ.

កែវ ពិសី

### ខ. លិខិតសំដែងសេចក្ដីរីករាយចំពោះបុត្ររបស់មិត្រដែលទើបនឹងបានប្រឡងជាប់

ថ្ងៃទី ២ សីហា ឆ្នាំ ១៩៩៩

បងរ៉ានីជាទីស្រឡាញ់.

ខ្ញុំមានសេចក្ដីរីករាយ ប្រញាប់ប្រញាល់សរសេរសំបុត្រនេះ ផ្ញើមក


www.elibraryofcambodia.org

ដើម្បីនាំយកពាក្យសរសើររបស់ខ្ញុំជូនចំពោះបុត្រារបស់បង ដែលទើបនឹងបាន ប្រឡងជាប់ថ្មីៗ នេះ ។ ខ្ញុំសប្បាយចិត្តចំពោះបង ហើយជាពិសេសចំពោះក្មួយ ដែលបានទទួលលទ្ធផលប្រពៃ អំពីការងាររបស់វា ។

សូមបងបញ្ជូនវាឱ្យទៅលេងកំសាន្តជាមួយនឹងយើងខ្ញុំក្នុងពេលវិស្សម-កាលធំនេះ ។ អាកាសធាតុនៅមាត់សមុទ្រនឹងធ្វើឱ្យមានសុខភាពល្អមិនខាន ។ ខួរក្បាលវាបានសំរាកលំហែ ហើយភ្លឺថ្លាផង អាស្រ័យនឹងការសប្បាយផ្សេងៗ នៅទីនោះ ។ បើបងអនុញ្ញាតឱ្យវាទៅលេងនឹងយើងខ្ញុំបានយូរ នោះយើងខ្ញុំរឹងរឹតតែរីករាយចិត្តណាស់ទៀត ហើយបើសិនជារូបបងបានអញ្ជើញទៅជាមួយនឹងវាផង សេចក្តីរីករាយរបស់យើងខ្ញុំមិនអាចរកអ្វីមកប្រៀបបានឡើយ ។ សូមបងកុំប្រកែកនឹងសេចក្តីស្នើអញ្ជើញរបស់យើងខ្ញុំឱ្យសោះ ។

សូមផ្ញើសេចក្តីគោរពចំពោះស្វាមីរបស់បង និង ក្មួយផង ។

**ហ៊ីម ស្រីនាង**

## គ-លិខិតក្រុមសិស្សថ្លែងអំណរអរគុណ ចំពោះគ្រូក្រោយពេលប្រឡងជាប់

សូមក្រាបប្រណិបតន៏ចូលមកលោកគ្រូ អ្នកគ្រូ

សូមទានជ្រាប,

យើងខ្ញុំទាំងឡាយជាសិស្សរបស់លោកគ្រូនិងអ្នកគ្រូនៃវិទ្យាល័យទួល-

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

ទំពូងពីឆ្នាំមុន. សូមលំឱនកាយគោរពថ្លែងអំណរគុណដ៏លើសលប់ ចំពោះលោកគ្រូ ដោយលោកគ្រូបានណែនាំបង្ហាត់បង្រៀនយើងខ្ញុំគ្រប់គ្នាឱ្យបានចេះស្ទាត់នូវវិជ្ជាផងផងទាំងពួង ត្រាតែបានទទួលជ័យជំនះបរិបូណ៌ក្នុងការប្រឡងយកសញ្ញាប័ត្រដែលកន្លងមកហើយនេះ ។ យើងខ្ញុំពុំភ្លេចទេ ព្រះគុណរបស់លោកគ្រូដែលតែងខំព្យាយាមរិះរកនូវខ្លឹមសាររបស់វិជ្ជាគ្រប់ជំពូក មកផ្សាយដល់យើងខ្ញុំជាសិស្សឱ្យបានងាយយល់នឹងបានចេះចាំគ្រប់វិជ្ជាប្លែក១ ទាំងនេះផង ។ ដោយសារព្រះគុណនេះហើយ ទើបយើងខ្ញុំជៀសផុតពីអំពើអាមាសមុខក្នុងការប្រឡងគ្រប់១ គ្នា ។

ទីបំផុត យើងខ្ញុំមិនដឹងនឹងរកពាក្យណាមកថ្លែងឱ្យបានស្មើនឹងព្រះគុណរបស់លោកគ្រូនិងអ្នកគ្រូដែលមានមកលើរូបយើងខ្ញុំទេ មានតែនាមគ្នាផ្គងហត្ថទាំងគូ ប្រណម្យចំពោះវត្ថុសក្ដិសិទ្ធិនានា សូមមកជួយប្រសិទ្ធិនូវពរជ័យជូនដល់លោកគ្រូនិងអ្នក ព្រមទាំងគ្រួសារ សូមឱ្យបានជួបប្រទះនឹងសេចក្ដីសុខ-ចំរើន គ្រប់កាលទិវារាត្រីកុំបីឃ្លៀងឃ្លាតឡើយ ។

តំណាងក្រុងសិស្សានុសិស្ស

ស៊ុម-ចរិយា

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

# IV-លិខិតសំរាប់គ្រួសារ

រាល់លិខិតទាំងឡាយដែលកូនណាមួយសរសេរផ្ញើទៅជូនឪពុកម្ដាយ ឬ ឪពុកម្ដាយផ្ញើជូនទៅកូនវិញ ឬមួយគេផ្ញើទៅកាន់ញាតិសន្ដាន ឬមិត្តភក្ដិណាដែលនៅឆ្ងាយ ហៅថា "លិខិតសម្រាប់គ្រួសារ" ទាំងអស់ ។ ហេតុនេះ សំបុត្រប្រភេទនេះ ងាយសរសេរជាងបំផុត ព្រោះមនុស្សដែលសរសេរផ្ញើទៅនោះសុទ្ធតែជាមនុស្សធ្លាប់ស្និទ្ធស្នាលគ្នារួចហើយ មិនចាំបាច់ប្រើពាក្យផ្ញែផ្ញូរពេកទេ គឺគ្រាន់តែប្រើពាក្យសាមញ្ញដែលធ្លាប់ប្រើនៅក្នុងគ្រួសារមួយៗ បានហើយ តែកុំប្រើពាក្យមិនគួរស្ដាប់ពេក ដូចជាៈ អញ វា ហង អាឯង... ជាដើម ។ ក្នុងសំបុត្រសំរាប់គ្រួសារនេះ គេសរសេរចោះៗ យកតែការដែលសំខាន់ ៗ មកនិយាយ បើសិនជាមានការ. ចំណែកឯរឿងសួរសុខទុក្ខគ្នាទៅវិញទៅមកវិញ គេមិនប្រកាន់ទេ ទោះបីជាចង់និយាយវែងឬរាប់រៀបច្រើនបន្តិចក៏មិនទាស់ដែរ ដ្បិតគេចង់សម្ដែងទឹកចិត្តទឹករលីករបស់គេ ។

គំរូលិខិតខាងក្រោមនេះ ជាសេចក្ដីលិខិតសំរាប់គ្រួសារ :

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

# ១_លិខិតសិស្សផ្ញើទៅឪពុកម្ដាយ

ផ្ទះលេខ ១៧០B ផ្លូវលេខ ១៦៧ ចំការមន

ភ្នំពេញ. ថ្ងៃទី ៣០ តុលា ១៩៩៩

សូមក្រាបប្រណិបតន៍ ចូលមកលោកឪពុកនិងអ្នកម្ដាយ

សូមទានជ្រាប

អស់រយៈជាច្រើនថ្ងៃខែកន្លងមកហើយ ដែលកូនបានចាកចេញពីស្រុកកំណើតនិងអ្នកមានគុណទាំងពីរ ដើម្បីមកបន្តការសិក្សានៅទីក្រុងភ្នំពេញ ។ ពេលវេលាចេះតែកន្លងទៅហួសទៅជាលំដាប់ កូនតែងនឹកមមៃមកដល់ក្រុមគ្រួសារយើងដែលនៅឆ្ងាយ មិនដឹងជាបានជួបនឹងសេចក្ដីសុខ-ទុក្ខយ៉ាងណា ។ ប្រសិនណាបើលោកឪពុក-អ្នកម្ដាយព្រមទាំងបងប្អូនមីងមាយាយតា មានសេចក្ដីសុខជានិច្ចដូចចិត្តប្រាថ្នាហើយ នោះកូនមានសេចក្ដីត្រេកអរក្រៃលែងស្មើរតែរកអ្វីមកប្រៀបពុំបានឡើយ ។

ចំណែកខ្លួនកូននៅសិក្សារៀនសូត្រសព្វថ្ងៃនេះវិញ ក៏បានគុណបុណ្យអ្នកមានគុណទាំងពីរជួយឱ្យបានសេចក្ដីសុខកាយជានិច្ចរៀងមក មិនដែលមានជម្ងឺឈឺថ្កាត់អ្វីទេ ព្រួយមួយតែពីការរៀនសូត្រដែលចេះតែមានវិជ្ជាប្លែកៗជារៀងរាល់ថ្ងៃ ។ ឯផ្ទះសម្បែងនិងម្ហូបអាហារវិញ លោកអ៊ុំគាត់បានទំនុកបំរុងកូនបានគ្រប់គ្រាន់ឥតដែលព្រួយបារម្ភសោះឡើយ ។

ឯចំណែកការសិក្សារបស់កូនវិញ គ្មានបញ្ហាអ្វីទេ កូនបានទទួល

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

សេចក្ដីស្រឡាញ់និងការកោតសរសើរពីមិត្តភក្ដិ និងលោកគ្រូអ្នកគ្រូជាច្រើន ។

ទីបញ្ចប់នៃសំបុត្រនេះ កូនសូមលើកហត្ថាឡើងប្រណម្យបួងសួងដល់គុណកែវទាំងបី សូមលោកជួយទ្រទ្រង់លោកអ្នកមានគុណព្រមទាំងគ្រួសារយើងឱ្យបានជួបប្រទះនឹងសេចក្ដីសុខ កុំបីមានទុក្ខមកបៀតបៀនបានឡើយហោង ។

ពីកូនសំឡាញ់របស់លោកអ្នកមានគុណ.

**នាក់_សំអឿន**

## ២_លិខិតឆ្លើយតបពីឪពុកម្ដាយ

តាកែវ. នៅថ្ងៃទី ១២ វិច្ឆិកា ១៩៩៩

មកដល់**សំអឿន**កូនសំឡាញ់

ឪពុកនិងម្ដាយឯងបានទទួលសំបុត្រកូនតាំងពីមួយសប្ដាហ៍មុនម្ល៉េះ ហើយឪពុកបានអានឱ្យម្ដាយឯងស្ដាប់សព្វគ្រប់ហើយ តែឪពុករវល់នឹងធ្វើស្រែចំការមិនបានសរសេរតបមកកូនវិញឱ្យបានរួសរាន់ ។ ខ្លួនឪពុកក្ដីម្ដាយឯងក្ដីឬបងប្អូនឯងក្ដី ទាំងអស់គ្នាតែងតែនាំគ្នារលឹកដល់ឯងរាល់ថ្ងៃមិនដែលខាន ជាពិសេសក្មួយស្រីពៅរបស់ឯងដែលទើបតែចេះនិយាយបន្ដិចៗ នោះវាចេះតែហៅរកកូនឯងថា "ពូអឿនៗ" រាល់តែថ្ងៃ ។

តែមិនខុសពីសេចក្ដីប្រាថ្នារបស់ឯងទេ. ពុកនិងម្ដាយឯង ព្រមទាំង.

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

អ្នកទាំងអស់គ្នាតែងមានសេចក្ដីសប្បាយរីករាយដរាបមក មិនដែលមានរំខានឡើយ ។

ដើម្បីបំពេញសេចក្ដីខ្វះខាតរបស់កូន ឪពុកបានផ្ញើប្រាក់មួយចំនួនតាមរយៈអ៊ុំរបស់ឯង ទុកសំរាប់ចាយវាយចុះ ។ ប៉ុន្តែពុកសូមផ្ដាំមកកូនថា កុំបីចាយវាយខ្ជះខ្ជាយពេកទិញដូរតែរបស់ណាដែលត្រូវការចាំបាច់បានហើយ ដ្បិតមុខរបរពុកឆ្នាំនេះមិនសូវបានផលចំរើនដូចពីឆ្នាំមុនៗ ទេ ។ ត្រូវកូនយកចិត្តទុកដាក់ឱ្យមែនទែនចំពោះការរៀនសូត្រ ។

ពីឪពុករបស់កូន

**ប្រាក់_នេម**

## ៣_លិខិតរបស់កូនផ្ញើចំពោះម្ដាយ

ភ្នំពេញ, ថ្ងៃទី ២០ តុលា ១៩៩៩

អ្នកម្ដាយជាទីស្រឡាញ់

ថ្ងៃនេះជាថ្ងៃអាទិត្យ ខ្ញុំបានសំរាកពីការសិក្សា ហើយខ្ញុំមិនទៅដើរកំសាន្តនៅតាមតំបន់ទេសចរណ៍នានាដែរ ។ ខ្ញុំឆ្លៀតយកឱកាសនេះ សរសេរសំបុត្រមួយច្បាប់យ៉ាងវែងឆ្ងែងប្រាប់អ្នកម្ដាយអំពីជីវភាពសិក្សារបស់ខ្ញុំ ។

មហាវិទ្យាល័យដែលកូនរៀនមានអាគារខ្ពស់ៗ ដែលទើបនឹងសាងសង់ហើយថ្មី មានទីធ្លាធំទូលាយ មានបរិយាកាសបរិសុទ្ធ បន្ទប់រៀនទាំងឡាយ

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

មានពិតានខ្ពស់ៗព្រមទាំងបង្អួចយ៉ាងទូលាយ មានកង្ហាររច្រើនក្នុងបន្ទប់នីមួយៗ និងភ្លើងបំភ្លឺគ្រប់គ្រាន់ទាំងយប់ទាំងថ្ងៃ ។ ក្នុងបន្ទប់ទាំងនោះ អាកាសមិនក្តៅស្អុះស្អាប់ទេ ពីព្រោះមានខ្យល់ចេញចូលល្អ គួរឱ្យចង់រៀនណាស់ ។

សាស្ត្រាចារ្យទីមួយរបស់ខ្ញុំ គឺលោកម៉ារីន ។ លោកនេះមានមាឌខ្ពស់ កោរពុកមាត់ស្អាត តឹងរឹងនឹងសិស្សគាត់បន្តិច ។ ប៉ុន្តែខ្ញុំស្រឡាញ់លោកទៅវិញ ពីព្រោះកាលបើខ្ញុំមិនយល់ច្បាស់នូវសេចក្តីពន្យល់របស់លោក លោកខំអធិប្បាយពន្យល់ខ្ញុំទៀត លុះត្រាតែខ្ញុំបានយល់ច្បាស់ ។

សាស្ត្រាចារ្យទាំងអស់ និងមិត្តរួមថ្នាក់ទាំងអស់ ម្នាក់ៗ បញ្ចេញអាកប្បកិរិយាល្អ ស្រឡាញ់រាប់អានចំពោះខ្ញុំ ហើយតែងពោលសរសើរពីលទ្ធផលនៃការសិក្សារបស់ខ្ញុំថា ជាសិស្សម្នាក់មានបញ្ញាឈ្លាសវៃ យកចិត្តទុកដាក់នឹងការសិក្សា រៀនពូកែ និងសុភាពរាបសារ ។ ហើយពេលខ្លះ បើមិត្តភក្តិខ្ញុំមិនសូវយល់មេរៀន ពួកគាត់សូមខ្ញុំឱ្យជួយពន្យល់គាត់ ។

ទីបញ្ចប់នេះ កូនសូមជូនពរអ្នកម្តាយនិងគ្រួសារយើងមានសុភមង្គលជានិច្ចនិរន្តរ៍តទៅ ។

ពីកូនអ្នកម្តាយ

**នាក់ សំអឿន**

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

# ៤.លិខិតរបស់ម្ដាយផ្ញើទៅឱ្យកូន

តាកែវ, ថ្ងៃទី ៣១ កញ្ញា ១៩៩៩

កូនសំឡាញ់របស់ម្ដាយ

ម្ដាយអរគុណឯង ដែលបានសរសេរសំបុត្រមានអត្ថរសល្អផ្ញើទៅឱ្យម្ដាយ ។ ដើម្បីជារង្វាន់ដល់ឯង ម្ដាយផ្ញើមកនេះនូវប្រាក់មួយចំនួន តែចូរឯងកុំចាយវាយខ្ជះខ្ជាយពេក ព្រោះជីវភាពគ្រួសារយើងសព្វថ្ងៃនេះដូចជាមានការលំបាកច្រើន ស្រែចំការក៏ធ្វើមិនសូវបានផល ។

បងប្អូនប្រុសស្រី តែងរំឭកដល់រឿងឯងជានិច្ច ហើយការបាត់មុខឯងធ្វើឱ្យពួកវានឹកឯងណាស់ ។

ក្នុងប៉ុន្មានថ្ងៃនេះ សួនផ្ទះយើងមានទិដ្ឋភាពល្អប្រពៃ ។ រុក្ខជាតិទាំងឡាយប្រកបដោយស្លឹកពណ៌លឿងខ្ចីល្អ ឯបុប្ផាវិញក៏រីកស្គុសស្គាយពេញក្នុងសួនដែរ ។

ឥឡូវនេះ ម្ដាយត្រូវបញ្ចប់សំបុត្រត្រឹមហ្នឹងហើយយកទៅដាក់ឯមន្ទីរប្រៃសនីយ៍យ៉ាងរហ័ស ដើម្បីកូនឯងបានទទួលក្នុងព្រឹកថ្ងៃអាទិត្យនេះ ហើយពេលទំនេរចូរឯងឧស្សាហ៍សរសេរទៅលេងម្ដាយផង ។

ចូរកូនឯងខំថែរក្សាសុខភាពឱ្យបានល្អ នឹងកុំខ្ជះខ្ជាយពេលវេលាពេក ។

ម្ដាយមានសង្ឃឹមថាកូននឹងបានទទួលផលប្រយោជន៍យ៉ាងប្រពៃទៅ

www.budinst.gov.kh www.elibraryofcambodia.org

ពេលដែលទៅនៅឯថ្មពេជ្រ ។

ចូរកូនឯងនាំយកសេចក្តីគោរពអំពីម្តាយ ជូនដល់អ្នកស្រី និង លោក ស៊ុម-សមផង ។

ម្តាយជាទីស្រឡាញ់របស់កូន

**ស.មៅ**

## ៥.លិខិតក្មួយស្រីផ្ញើទៅឪពុកធំ.ម្តាយធំ

ភ្នំពេញ, ថ្ងៃទី ០៥ មិថុនា ១៩៥៩

សូមជំរាប់សួរមកដល់លោកអ៊ំទាំងពីរ

សូមជ្រាប,

អស់រយៈពេលជាច្រើនខែឆ្នាំណាស់មកហើយដែលក្មួយមិនបានសរសេរ មកលេងនឹងលោកអ៊ំទាំងពីរ ដោយសារការរៀនសូត្រចេះតែមមារញឹក ខ្លាំងពេក, តែក្មួយតែងតែនឹកមមែមកដល់លោកទាំងពីរជារឿយៗ ព្រោះមិន ដឹងជាបានសុខស្រួលឬមួយទុក្ខយ៉ាងណា ។

ចំណែកក្មួយព្រមទាំងប៉ា-ម៉ាក់ នឹងប្អូនតូចៗ របស់ក្មួយវិញ មានសេចក្តី សុខសប្បាយទាំងអស់គ្នាឥតមានជម្ងឺអ្វីមកបៀតបៀនទេ ។ ឯស្រីពេជ្រប្អូន ពៅខ្ញុំ វាចេះតែរលឹកមកលោកអ៊ំទាំងពីរសឹងតែរាល់ថ្ងៃ វាចេះតែសួរម៉ាក់ ថា "ណាអ៊ំ!ៗ" ម៉ាក់សួរវាថាអ៊ំណា? វាឆ្លើយថាអ៊ំនៅភ្នំពេញ តែវានិយាយ

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

មិនច្បាស់ឮតែថា "អ៊ំប៉ញ១" ទៅវិញ ។ សព្វថ្ងៃនេះបើកាលណាវាឃំ គេគ្រាន់តែភូតវាថា នុំះអ៊ំប៉ុញមកហើយ ។ គ្រាន់តែឮបាត់ឃំភ្លាម ព្រោះវាជឿថាតែអ៊ំអញ្ជើញមកមុខជាយកផ្លែប៉ោមឱ្យញ៉ាំទៀតហើយ ។

ដូច្នេះ នៅឱកាសបុណ្យអុំទូកនិងអកអំបុកខាងមុខនេះ ខ្ញុំក្មួយព្រមទាំងប៉ាក់-ម៉ាក់ សូមអញ្ជើញលោកលោកអ៊ំទាំងពីរមកលេងក្រុងភ្នំពេញដើម្បីទស្សនា ព្រះរាជពិធីនេះផងតែសូមអ៊ំអនុញ្ញាតឱ្យណារីមកជាមួយផង ព្រោះខានបានជួបណារីប្រហែលមួយឆ្នាំហើយ ។ ក្មួយចង់ណែនាំណារីឱ្យស្គាល់មិត្រនារីរបស់ក្មួយឯទៀត ដែលរៀននៅវិទ្យាស្ថានជាតិគ្រប់គ្រង ។ បានជាចង់ដូច្នេះ ដ្បិតក្មួយដឹងថា នៅចុងឆ្នាំនេះណារីត្រូវប្រឡងចូលមហាវិទ្យាល័យនេះដែរ ។

ហេតុនេះ ក្មួយព្រមទាំងគ្រួសារនាំគ្នាចាំទន្ទឹងផ្លូវលោកអ៊ំទាំងពីរនឹងណារីនៅពេលពិធីបុណ្យអុំទូកខាងមុខនេះជាមិនខាន ។

ក្មួយស្រីរបស់អ៊ំទាំងពីរ

**ឡូយ នីតា**

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

# V-លិខិតពាណិជ្ជកម្ម ឬ ជំនួញ

អ្វីទៅដែលហៅថា "លិខិតពាណិជ្ជកម្ម" ? លិខិតពាណិជ្ជ ឬមុខជំនួញ គឺជាលិខិតដែលនិយាយតែពីការខាងជំនួញ និងទាក់ទងគ្នាខាងពាណិជ្ជកម្ម ។ ដូច្នេះលិខិតនេះ មិនចាំបាច់រាប់រៀបពីសុខ-ទុក្ខប្រាប់គ្នាទៅវិញទៅមកនោះទេ គឺនិយាយតែប្រការសំខាន់ទៅលើការឱ្យដំណឹងទៅវិញទៅមកពីមុខរបររៀងខ្លួន ។ នៅខាងចុងបំផុត គេគ្រាន់តែបញ្ចូលពាក្យគួរសមខ្លះជាការល្អមើលប៉ុណ្ណោះ ។

ដូច្នេះគួរប្រយ័ត្នក្នុងការសរសេរសំបុត្ររបៀបនេះ កុំឱ្យវែងឥតប្រយោជន៍នាំពិបាកស្តាប់ទៅជាមិនបានការទៅវិញ ។

លិខិតពាណិជ្ជកម្មខាងក្រោមនេះ គួរតែយើងសរសេរដោយប្រយ័ត្ន :

## ១-លិខិតជូនដំណឹងពីក្រុមហ៊ុនលក់រថយន្ត

លោកឧត្តម

ក្រុងព្រះសីហនុ

ខ្ញុំមានសេចក្តីរីករាយទំនងជំរាបលោកថា ក្រុមហ៊ុនយើងខ្ញុំទើបនឹងបើកដោយដាក់នាមថា "ហុងដា" លេខ ១៦៥ AE1 វិថីម៉ៅស៊ីទុង សំរាប់លក់រថយន្តនិងទោចក្រយានយន្ត ព្រមទាំងគ្រឿងបន្លាស់គ្រប់ធុន ។

ដូច្នេះ បើលោកត្រូវការទទួលយកទៅលក់រាយតទៅទៀតនៅតាម

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

ខេត្តនានា សូមអញ្ជើញមកផ្ទាល់ឬក៏ផ្ញើសំបុត្របញ្ជាទិញមកខ្ញុំ ខ្ញុំនឹងចាត់ចែងទៅជូនឱ្យបានឆាប់ទាន់ចិត្ត ដោយជូនកម្រៃ ១៥ ភាគរយលើថ្លៃលក់ទៀត ។

សូមលោកទទួលនូវមេត្រីភាពអំពីខ្ញុំ ។

ភ្នំពេញ. ថ្ងៃ ១១ សីហា ១៩៩៩

( ហត្ថលេខា)

## ២_លិខិតសួរថ្លៃ និង សុំគំរូ

លោកចាងហ្វាងក្រុមហ៊ុនហុងដា

ក្រុងភ្នំពេញ

ដោយខ្ញុំទើបទទួលដំណឹងថាក្រុមហ៊ុនរបស់លោក ទើបតែនឹងបើកលក់យានយន្តនិងទោចក្រយានយន្ត ព្រមទាំងគ្រឿងបន្លាស់គ្រប់ធុន ។ ដូច្នេះខ្ញុំសូមឱ្យលោកមេត្តាចាត់ការផ្ញើនូវគំរូទាំងនេះ ព្រមទាំងប្រាប់ថ្លៃក្នុងមួយគ្រឿងប៉ុន្មានៗ ឱ្យបានឆាប់មកខ្ញុំផង ។ ខ្ញុំនឹងបញ្ជូនបណ្ណបញ្ជាទិញទៅជាក្រោយនៅពេលដែលបានពិនិត្យមើលគំរូទាំងនោះហើយ ។

ក្នុងពេលរង់ចាំគំរូរបស់លោក ខ្ញុំសូមថ្លែងនូវមេត្រីភាព ដ៏ស្មោះចំពោះលោក ។

ក្រុងព្រះសីហនុ ថ្ងៃទី ២៥ សីហា ១៩៩៩

( ហត្ថលេខា)

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

## ៣_លិខិតឆ្លើយតបនឹងលិខិតសួរថ្លៃនិងសុំគំរូ

លោកឧត្តម....

ក្រុងព្រះសីហនុ

ខ្ញុំបានទទួលលិខិតលោកចុះថ្ងៃទី ២៥ សីហា ១៩៩៩ ដែលសួរពត៌មានពីរថយន្តនិងទោចក្រយានយន្ត ព្រមទាំងគ្រឿងបន្លាស់មកដល់ថ្មីនឹងសុំឱ្យខ្ញុំផ្ញើគំរូទៅជូន ។ ថ្ងៃនេះ ខ្ញុំបានផ្ញើរថយន្ត និងទោចក្រយានយន្ត ព្រមទាំងគ្រឿងបន្លាស់ជាច្រើនប្រភេទ ព្រមទាំងថ្លៃភ្ជាប់ដាក់ជាមួយស្រាប់ សូមលោកទទួលយកទៅពិនិត្យតាមត្រូវការចុះ ។

ខ្ញុំសង្ឃឹមថា លោកមុខជានឹងតបមកខ្ញុំវិញក្នុងពេលយ៉ាងឆាប់ ព្រមទាំងបញ្ជាក់ប្រាប់ខ្ញុំពីរបៀប តើលោកចង់ឱ្យខ្ញុំផ្ញើតាមរថភ្លើងឬតាមផ្លូវរថយន្តដើម្បីបានងាយនឹងចាត់ការឱ្យបានស្រួលក្នុងរឿងនេះ ។

សូមលោកទទួលមេត្រីភាពពីខ្ញុំ ។

ភ្នំពេញ. ថ្ងៃទី ២៩ សីហា ១៩៩៩

ចាងហ្វាងក្រុងហ៊ុនហុងដា

(ហត្ថលេខា)

www.budinst.gov.kh www.elibraryofcambodia.org

# ៤-បញ្ជាទិញទំនិញ

លោកចាងហ្វាងក្រុមហ៊ុនហុងដា

ក្រោយពីបានទទួលសេចក្ដីជូនដំណឹងរបស់លោក ខ្ញុំត្រូវការទិញទោចក្រយានយន្តមួយចំនួន ។

សូមលោកចាត់ការផ្ញើនូវទោចចក្រយានយន្តដូចមានតារាងភ្ជាប់មកជាមួយនេះ :

(បញ្ជីរាយមុខរបស់ដែលត្រូវការទិញ)

គំរូទាំងនោះ សូមលោកផ្ញើមកខ្ញុំតាមរថយន្តចុះ ដ្បិតឆាប់បានដល់ហើយ ។ សូមលោកផ្ញើភ្ជាប់មកជាមួយវិក័យប័ត្រ ដោយរាយតម្លៃមួយមុខៗនឹងថ្លៃបូករួមមកផង ដើម្បីខ្ញុំផ្ញើប្រាក់ទៅជូនលោកតាមត្រៃសណីយ៍ នៅវេលាណាវត្ថុទាំងនេះមកដល់ហើយ ។

ក្រុងព្រះសីហនុ, ថ្ងៃទី ៥ ខែ តុលា ឆ្នាំ ១៩៩៩

(ហត្ថលេខា)

www.budinst.gov.kh www.elibraryofcambodia.org

## ៥_លិខិតប្រគល់ទំនិញ

លោកឧត្តម

ក្រុងព្រះសីហនុ

តាមសំបុត្រលោកចុះថ្ងៃទី ០៥ តុលា ១៩៩៩ ដែលភ្ជាប់នឹងប័ណ្ណបញ្ជាទិញមួយនោះ ខ្ញុំបានផ្ញើនូវទំនិញគ្រប់ចំនួនតាមប័ណ្ណនោះហើយ ដូច្នេះសូមលោកចុះហត្ថលេខាលើបណ្ណប្រគល់របស់ខ្ញុំលេខ ១២១ នេះ រួចផ្ញើមួយសន្លឹកត្រឡប់មកឱ្យខ្ញុំវិញ ទុកសំរាប់ធ្វើវិក័យប័ត្រផ្ញើទៅជាក្រោយ ។

សូមលោកទទួលនូវរបស់តាមត្រូវការ នឹងសូមទទួលយកសេចក្ដីរាប់អានយ៉ាងស្មោះអំពីខ្ញុំ ។

ភ្នំពេញ, ថ្ងៃទី ៨ តុលា ១៩៩៩

ប្រធានក្រុមហ៊ុន

(ហត្ថលេខា)

## ៦_លិខិតផ្ញើទៅសុំខ្ចីប្រាក់

ប្រាំបីមុំ, ស្រុកទ្រាំង ខេត្តតាកែវ

ថ្ងៃទី ២៣ កក្កដា ១៩៩៨

សំឡាញ់ជាទីស្នេហា

សំឡាញ់តែងបានបញ្ចេញចំពោះខ្ញុំ នៅពេលឃើញស្គាល់ក្នុងមិត្តភាព

www.budinst.gov.kh www.elibraryofcambodia.org

www.elibraryofcambodia.org

ជានិច្ច នាំឱ្យខ្ញុំហ៊ានរត់រកសំឡាញ់ នៅពេលដែលខ្ញុំជួបប្រទះស្ថានភាពដ៏លំបាក ។

ពេលនេះខ្ញុំត្រូវការប្រាក់ចំនួនមួយរយដុល្លារ ដែលខ្ញុំនឹងជូនមកសំឡាញ់វិញក្នុងបួនខែខាងមុខនេះ ។

ខ្ញុំសូមដឹងគុណដ៏ជ្រាលជ្រៅ ចំពោះសំឡាញ់បើសិនសំឡាញ់ផ្ញើចំនួនប្រាក់នោះទៅខ្ញុំ ក្នុងពីរ-បីថ្ងៃបន្ទាប់នេះ ។

ស្នេហាភាពយ៉ាងខ្ពង់ខ្ពស់

**ហ៊ឹម ស៊ីថា**

## ៧_លិខិតថ្លែងអំណរគុណដល់មិត្តដែលឱ្យខ្ចីប្រាក់

ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៩៨

ប្រាំបីមុំ, ស្រុកទ្រាំង ខេត្តតាកែវ

សំឡាញ់ជាទីស្នេហា,

ខ្ញុំទើបនឹងបានទទួលអាណត្តិ-ប្រៃសណីយ៍ ដែលសំឡាញ់ផ្ញើទៅឱ្យខ្ញុំ ហើយខ្ញុំសរសេរសំបុត្រនេះយ៉ាងប្រញាប់ផ្ញើមកសំឡាញ់ដើម្បីជ្រាបជាដំណឹង ។

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

ខ្ញុំសូមថ្លែងអំណរគុណដ៏ទូលំទូលាយអស់ពីដួងចិត្តចំពោះសំឡាញ់ ដែលបានផ្ញើប្រាក់ទៅឱ្យខ្ញុំខ្ចី ដោយសុទ្ធចិត្ត ។ អំពើនេះចាត់ទុកជាអំពើប្រពៃមួយ ពីព្រោះបើគ្មានសំឡាញ់ទេ រូបខ្ញុំមិនដឹងជាធ្លាក់ទៅក្នុងការលំបាកយ៉ាងណាៗ ឡើយ ។

ខ្ញុំសូមបញ្ជាក់ថា ក្នុងគ្រាក្រ ពិបាករកមិត្តដែលល្អដូចសំឡាញ់នេះណាស់ ។ ខ្ញុំដឹងគុណសំឡាញ់អស់មួយជីវិត ។

ចំណែកប្រាក់នេះខ្ញុំនឹងលៃលកសងសំឡាញ់បន្តិចម្តងៗ ឱ្យអស់មុនដាច់ឆ្នាំនេះ ។

សូមសំឡាញ់ទទួលម្តងទៀតនូវសេចក្តីដឹងគុណដ៏ជ្រាលជ្រៅពីខ្ញុំ ។

**ហ៊ឹម ស៊ីថា**

## ៨. លិខិតផ្ញើទៅទារបំណុល

ភ្នំពេញ, ថ្ងៃទី ១៣ វិច្ឆិកា ១៩៩៨

**មិត្តស៊ីថា**

កាលពីព្រឹកមិញ ខ្ញុំបានទៅរកមិត្តក្នុងវត្តបំណងសុំយកវិញ នូវចំនួនប្រាក់ ៣០០.០០០ រៀល ដែលមិត្តបានខ្ចីខ្ញុំ កាលពីខែមុននេះ តែខ្ញុំគ្មានសំណាង មិនបានជួបនឹងមិត្តសោះ ។

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

- ដូច្នេះ ជាការចាំបាច់ សូមមិត្តមេត្តាផ្ញើចំនួនប្រាក់នោះទៅខ្ញុំយ៉ាងប្រញាប់ ព្រោះខ្ញុំត្រូវការខានមិនបាន ។

សូមមិត្តអភ័យទោសឱ្យខ្ញុំ ខ្ញុំសង្ឃឹមលើមិត្ត និងចាប់ដៃមិត្តពីចម្ងាយក្នុងមិត្តភាពដ៏ខ្ពង់ខ្ពស់ ។

ស៊ីន-តាំង្រ្គា

## ៩-លិខិតសុំអភ័យទោសអំពីម្ចាស់បំណុល

តាកែវ, ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ១៩៥៨

ជំរាបលោកសូមជ្រាប

ក្នុងខែកន្លងហើយនេះ ខ្ញុំមិនបានទទួលប្រាក់អាណត្តិប្រែសនីយពីឪពុកខ្ញុំ ដូចខ្ញុំធ្លាប់បានទទួលរៀងរាល់ខែនោះឡើយ ហេតុនេះខ្ញុំមិនអាចសងប្រាក់លោកភ្លាមៗ បានទេ ។

សូមលោកមេត្តា រង់ចាំដល់ដាច់ខែសិន ហើយសូមជឿជាក់ថា ខ្ញុំមានសេចក្តីស្តាយក្រៃពេក ដោយមិនបានធ្វើឱ្យលោកសប្បាយចិត្តក្នុងពេលនេះ និងសូមឱ្យលោកសង្ឃឹមលើកិត្តិយសនិងសច្ចវាចារបស់ខ្ញុំចុះ ។

សូមលោកទទួលនូវសេចក្តីគោរពពីខ្ញុំ

ហ៊ឹម ស៊ីថា

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

# VI-លិខិតផ្លូវការ និងទាក់ទងនឹងរាជការ

លិខិតនេះ ជាគំរូមួយបែបផ្សេងពីគេ គឺគេសរសេរមានបែបផែនល្អណាស់ នឹងផ្ចិតផ្ចង់សេចក្ដីឱ្យសមរម្យទៀត ។ ខាងដើមនៃលិខិតនេះ គេត្រូវប្រយ័ត្នចំពោះការសរសេរដាក់ងារសក្តិរបស់មន្ត្រី ដែលយើងត្រូវប្រាស្រ័យទាក់ទងជាមួយ ដ្បិតមន្ត្រីទាំងឡាយសុទ្ធសឹងមានយសសក្តិនឹងគោរម្យងារផ្សេងៗ គ្នា ។ តាមរបៀបជាន់មុនខ្មែរ យើងសរសេរលិខិតចំពូកនេះច្រើនដាក់ឈ្មោះអ្នកមានការប្រស្រ័យនឹងអ្នករាជការនោះមុន រួចទើបដាក់គោរម្យងារមន្ត្រីក្រោយ ។ តែបើតាមការសង្កេតចំពោះរបៀបសរសេរជាសាកលវិញឃើញរបៀបនេះឆ្គងបន្តិច ។ ដូច្នេះ ត្រូវដាក់គោរម្យងារមន្ត្រីជាមុន រួចសឹមដាក់ឈ្មោះយើងអ្នកមានការជាខាងក្រោយទើបសមរម្យជាង ។

## ១-លិខិតឱ្យទៅស្នាម

មកដល់**វិជ្ជិកា**

ខ្ញុំសរសេរសំបុត្រនេះដើម្បីបង្ហាញជូនពីមិត្តដ៏ល្អម្នាក់របស់យើង ឈ្មោះ **វាសនា** គាត់ទៅដល់អង្គការនាងក្នុងប៉ុន្មានថ្ងៃនេះ ។ ខ្ញុំរំពឹងថា អ្នកទាំងពីរនិងបានជួបគ្នាដោយបណ្ដាមិត្តបានយកចិត្តទុកដាក់ដល់

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

បញ្ហាតែមួយៈ សុខមាលភាពរបស់កុមារ ។

**ទាវសនា** កំពុងស្រាវជ្រាវអំពីការប្រព្រឹត្តបទល្មើសរបស់កុមារជំទង់ ទើបខ្ញុំបានរ៉ាយរ៉ាប់ប្រាប់គាត់អំពីការងារដែលគួរឱ្យចាប់ចិត្តដែលនាងកំពុងដំណើរការ ស្តីពីកុមារត្រូវបាត់បង់សិទ្ធិនៅអង្គការនាង ។ គាត់ចង់ពិគ្រោះយោបល់ជាមួយនាងអំពីបញ្ហានោះ ខ្ញុំជឿថានាងចូលចិត្តជួប **ទាវសនា** ណាស់ហើយផ្ទុយមកវិញខ្ញុំក៏ដឹងថា គាត់ក៏សប្បាយរីករាយណាស់និងចង់ជួបនាងណាស់ដែរ ។

ដោយក្តីរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ

**កែវ ធីតា**

## ២_លិខិតសុំអនុញ្ញាតរៀបអាពាហ៍ពិពាហ៍

ផ្ទះលេខ ១៧០B ផ្លូវលេខ ១៦៧, ភ្នំពេញ

មក្រាបប្រណិប័តន៍ចូលមកលោកចៅសង្កាត់

ទួលទំពូង II ខណ្ឌចំការមន.

សូមទានជ្រាប

ខ្ញុំបាទឈ្មោះ **ស៊ឹម_សម** អាយុ ៥៤ ឆ្នាំ ជាតិខ្មែរ ភរិយាឈ្មោះ **ហ៊ឹម_សារីម** មុខរបរធ្វើយោធា នៅក្នុងអង្គភាពដឹកជញ្ជូនផ្លូវគោក.

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

រាជធានីភ្នំពេញ ។

ដោយខ្ញុំបាទត្រូវរៀបអាពាហ៍ពិពាហ៍កូនស្រីឈ្មោះ**ស៊ុម សក្ខិណា** អាយុ ១៨ ឆ្នាំ ឱ្យទៅជាគូនឹងឈ្មោះ **នាក់ សំអឿន** អាយុ ២៥ ឆ្នាំ ធ្វើការប្រធានក្រុមហ៊ុនលក់រថយន្តឡង់គ្រីសឺរ ជាកូនរបស់លោក **ក្រាក់ នេម** នឹងអ្នកស្រី**ស ម៉ៅ** មានទីលំនៅ។ ភូមិគ្រឹះលេខ ២៤z មហាវិថីនរោត្តម ក្រុងភ្នំពេញ នៅថ្ងៃទី ពេញបូរមីខែកត្តិក ត្រូវនឹងថ្ងៃទី ៣០ វិច្ឆិកា ឆ្នាំ ២០០៥ ខាងមុខនេះ ។ ហេតុនេះសូមលោកចៅសង្កាត់មេត្តាចេញប្រកាសផ្សាយដំណឹងនេះ ឱ្យបានមុនក្នុងរវាង ១០ ថ្ងៃមុនពេលរៀបចំពិធីអាពាហ៍ពិពាហ៍ ដើម្បីការពារនឹងពាក្យតវ៉ាផ្សេង។ ។

សូមលោកទទួលនូវគារវភាពអំពីខ្ញុំបាទ ។

ហត្ថលេខា

**ស៊ុម សម**

## ៣. លិខិតផ្ញើទៅសាលារៀន

ភ្នំពេញ, ថ្ងៃទី ២៧ តុលា ១៩៥៨

សូមគោរពលោក

ប្រសិនបើលោកនៅមានសល់កន្លែងសម្រាប់សិស្សម្នាក់រៀនធ្វើ

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

ការងារ ខ្ញុំនឹងអរគុណលោកណាស់ក្នុងការផ្ញើកូនប្រុសសុខារបស់ខ្ញុំ ក្រោមការបង្ហាត់បង្រៀនរបស់លោក ។ ដោយហេតុថាកូនប្រុសខ្ញុំនេះចង់រៀនវិជ្ជាសំណង់ទូទៅ ហើយខ្ញុំក៏ជឿដែរថា គ្មានវិស័យណាមួយ ដែលកូនខ្ញុំបង្ហាញថាមានប្រយោជន៍ជាងវិស័យនេះឡើយ ។ ឆ្នាំនេះកូនខ្ញុំអាយុ ១៩ ឆ្នាំ មាធធំហើយខ្ពស់ បើប្រៀបធៀបទៅនឹងអាយុវាធ្លាប់បានរៀននៅសាលា ..... តាមការពិនិត្យរបស់លោកគ្រូនាយក វាស័ក្តិសមជាមួយនិងការងារដូចកន្លែងលោកអញ្ជើង ។

ខ្ញុំអន្ទះសារដោយចង់ឱ្យវាបានទទួលឱ្យចូលក្នុងស្ថាប័នណាមួយកាន់តែឆាប់ កាន់តែល្អ ។ លោកអាចឆ្លើយតបវិញពីលក្ខខណ្ឌនៃការទទួលសិស្សបានដែរយ៉ាងណាតើលោកអាចទទួលកូនខ្ញុំបានដែរឬទេ? ខ្ញុំនឹងដឹងគុណលោកជានិច្ច ។

ដោយក្តីគោរពរាប់អានអំពីខ្ញុំ

**មុំ សារ៉ាត់**

******

ភ្នំពេញ, ថ្ងៃទី ២៥ មករា ១៩៩៩

មកដល់លោកនាយក

ខ្ញុំព្រួយបារម្ភណាស់នៅពេលទទួលបានតារាងសិក្សារបស់កូនរដ្ឋា

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

កាលពីម្សិលមិញ ។ ខ្ញុំបានអានយ៉ាងម៉ត់ចត់ ហើយហាក់ដូចជាឃើញថា ក្រៅពីមុខវិជ្ជាធម្មតាប៉ុន្មាននោះ ការរៀនសូត្ររបស់កូនខ្ញុំមិនបានពេញចិត្តខ្ញុំឡើយ ។

ជាបឋមខ្ញុំសូមឱ្យលោកនាយកយល់ថា ខ្ញុំគ្មានគំនិតប្រកែកប្រកាន់លោក ឬសមូហភាពគ្រូបង្រៀនអំពីរឿងនេះឡើយ ។ និយាយឱ្យស្មោះទៅ ខ្ញុំសូមលោកជួយកូនខ្ញុំនេះបន្ថែមទៀត ។ ខ្ញុំនិងអរគុណណាស់ ប្រសិនបើលោកអាចប្រគល់មេរៀនបន្ថែមទៀតឱ្យវា ដើម្បីឱ្យវាកាន់តែយកចិត្តទុកដាក់ជាងនេះ ហើយទុកពេលវេលាជាច្រើនសំរាប់ការរៀនសូត្រសព្វថ្ងៃចំពោះបណ្ដាមុខវិជ្ជាក្នុងសាលារៀន ។

ខ្ញុំយល់ថា ឪពុកម្ដាយតែងតែសន្ដោសប្រណីដល់កូន ប៉ុន្ដែខ្ញុំជឿជាក់វាអាចធ្វើបានគ្រាន់បើជាងអ្វី ដែលមាននៅក្នុងតារាងលទ្ធផលសិក្សារបស់វា ។

ខ្ញុំនឹងរីករាយណាស់ដោយបានសហការជាមួយលោកតាមវិធីណាក៏ដោយ ឱ្យតែលោកជួយជាយោបល់ ដើម្បីកែលំអស្ថានភាពដ៏ធ្ងន់ធ្ងរនេះ ។

ដោយសេចក្ដីគោរពពីខ្ញុំ

**សុវណ្ណ រិទ្ធី**

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

## ៤. លិខិតសុំអនុញ្ញាតសង់រោងធ្វើបុណ្យ

តាកែវ, ថ្ងៃទី ១៣ កក្កដា ១៩៩៨

សូមក្រាបប្រណិបតន៍ចូលមក

លោកសន្ទប់ឃុំប្រាំបីមុំ

សូមទានជ្រាប.

ខ្ញុំបាទឈ្មោះ **ហ៊ឹម ស៊ីថា** ជាតិខ្មែរមានទីលំនៅសព្វថ្ងៃនៅភូមិដំណាក់រាជា ក្នុងឃុំប្រាំបីមុំ ស្រុកទ្រាំង ខេត្តតាកែវ ។

សូមធ្វើលិខិតនាំចូលមកសុំអនុញ្ញាតពីលោកប្របាទម្ចាស់ ដើម្បីសង់រោងនៅលើចិញ្ចើមថ្នល់មុខផ្ទះខ្ញុំបាទ សំរាប់រៀបពិធីបច្ច័យបួន ដែលខ្ញុំបាទព្រមទាំងគ្រួសារនឹងបងប្អូនញាតិមិត្របានមូលមតិគ្នាប្រារព្ធពិធីបុណ្យនេះនៅថ្ងៃ សៅរ៍ទី ២០ កក្កដា ១៩៩៨ ដូចមានកម្មវិធីជាប់មកជាមួយនេះស្រាប់ ។

ហេតុនេះសូមលោកប្របាទម្ចាស់មេត្តាអនុញ្ញាតតាមសេចក្តីសុំរបស់ខ្ញុំបាទផង នឹងសូមទទួលយកនូវគារវភាពរបស់ខ្ញុំបាទ ។

ដោយសេចក្តីគោរពពីខ្ញុំ

**ហ៊ឹម ស៊ីថា**

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

## ៥. លិខិតផ្ញើទៅវេជ្ជបណ្ឌិត

ភ្នំពេញ, ផ្ទះលេខ ១៥Z ផ្លូវលេខ ២៣៨ ស្វាយព្រៃ II

ថ្ងៃទី ០៨ សីហា ១៩៩៩

គោរពជូនលោកវេជ្ជបណ្ឌិតចន្ទ្រាបុត្រ

ខ្ញុំមានការព្រួយបារម្ភណាស់ចំពោះស្ថានភាពសុខភាពរបស់ភរិយាខ្ញុំពីមួយថ្ងៃទៅមួយថ្ងៃ កាន់តែធ្ងន់ធ្ងរឡើងក្នុងប៉ុន្មានខែចុងក្រោយនេះ ។ ខ្ញុំនឹងដឹងគុណលោកណាស់ប្រសិនបើលោកឆាប់មកដល់ផ្ទះខ្ញុំនោះ ។

ខ្ញុំសរសេរសំបុត្រដោយមិនទូរស័ព្ទទៅលោកទេ ព្រោះខ្ញុំមិនចង់ឱ្យអ្នកផ្ទះដឹងពីកំរិតនៃការព្រួយបារម្ភរបស់ខ្ញុំ ។ តាំងពីចូលនិវត្តន៍នាទិឃារដូវឆ្នាំទៅមិញនេះ ភរិយាខ្ញុំហាក់បីដូចជាហូបបាយមិនដឹងឆ្ងាញ់ ហើយកាន់តែថមថយកម្លាំងទៅ ខ្ញុំក្រែងថាគាត់ត្រូវស្រកទម្ងន់ ។ កាលពីសប្តាហ៍មុននេះភរិយាខ្ញុំត្រូវជួបនឹងការឈឺក្រពះជាខ្លាំង ប៉ុន្តែគាត់មិនព្រមឱ្យខ្ញុំអញ្ជើញវេជ្ជបណ្ឌិតមកឡើយ ដោយហេតុថាកាលពីយប់មិញនេះមានការឈឺចាប់មួយទៀត ទើបខ្ញុំឃើញថាល្មមដល់ពេលដែលខ្ញុំធ្វើអ្វីមួយដើម្បីជួយភរិយាខ្ញុំហើយ។ ភរិយាខ្ញុំអាយុ ៤៥ ឆ្នាំហើយ ប៉ុន្តែក្រៅពីជម្ងឺផ្តាសាយពីរបងនោះគឺគាត់មានសុខភាពល្អធម្មតាទេ ។

ដោយសេចក្តីគោរពពីខ្ញុំ

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

# ៦.លិខិតសុំបង់ប៉ាតង់

ភ្នំពេញ, ថ្ងៃទី ១៨ សីហា ១៩៥៨

សូមក្រាបប្រណិបតន៍ចូលមកលោក

ប្រធានពន្ធដាររាជធានីភ្នំពេញ

សូមទានជ្រាប,

នាងខ្ញុំ ម្ចាស់ឈ្មោះ **ហ៊ឹម.សារឹម** អាយុ ៣៩ ឆ្នាំ ជាតិខ្មែរ របររកស៊ីធ្វើជំនួញនៅផ្សារធំថ្មី រាជធានីភ្នំពេញ ។

ដ្បិតនាងខ្ញុំ បានទិញតូបមួយនៅផ្សារធំថ្មីលេខ ៣៥ ដើម្បីលក់គ្រឿងអលង្ការ ( មាស ពេជ្រជាដើម) ។ ដូច្នេះ សូមចូលមកសុំអនុញ្ញាតពីលោកប្រធានពន្ធដារ ដើម្បីបង់នូវប៉ាតង់ជូនរាជការតាមកាលកំណត់របស់ច្បាប់ចាប់តាំងថ្ងៃនេះតទៅ សូមលោកប្រធានពន្ធដារមេត្តាអនុគ្រោះតាមពាក្យសុំរបស់នាងខ្ញុំផង ។

សូមលោកប្រធានពន្ធដារ មេត្តាទទួលយកនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់របស់នាងខ្ញុំ ។

ហត្ថលេខា

**ហ៊ឹម.សារឹម**

www.budinst.gov.kh www.elibraryofcambodia.org

# VII-លិខិតកិច្ចសន្យាជួលឬលក់វត្ថុនានា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចសន្យាជួលផ្ទះ

លោក ស៊ីវ_ដុស ភេទប្រុស អាយុ ៤៥ ឆ្នាំ សញ្ជាតិកម្ពុជា ដែលជាម្ចាស់ផ្ទះលេខ 15A ផ្លូវលេខ 328 ក្រុមទី 21 សង្កាត់ទូលស្វាយព្រៃទី ១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ហៅកាត់ ភាគី (ក) ។

លោកស្រី ឃុខា_គៀង ភេទស្រី អាយុ 42 ឆ្នាំ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ 097726 ភ.ព. ចុះថ្ងៃទី 3-4-1985 ហៅកាត់ថា ភាគី (ខ) ។

<u>ប្រការ១ :</u> ភាគី (ក) យល់ព្រមជួលផ្ទះលេខ ១៥A ជាន់ទី ១ ផ្លូវលេខ 328 ក្រុមទី 21 សង្កាត់ ទូលស្វាយព្រៃទី ១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ជូនដល់ ភាគី(ខ) ក្នុងរយៈពេលមួយឆ្នាំ គិតពី ថ្ងៃទី ០១-០៨-១៩៩៩ សំរាប់ស្នាក់នៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

<u>ប្រការ២ :</u> ភាគី (ខ) យល់ព្រមទូទាត់ជូន ភាគី (ក) តាមៈ

- តម្លៃឈ្នួលប្រចាំខែ ១០០ ដុល្លាអាមេរិក ក្នុងរយៈពេលមួយខែ

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

- ប្រាក់កក់ចំនួន ៣ ខែមុន ស្មើទឹកប្រាក់ ១០០ដុល្លា x ៣ខែ = ៣០០ ដុល្លា គឺចាប់ពីថ្ងៃ ទី ០១-០៨-១៩៩៩ រហូតដល់ ០១-០៩-១៩៩៩ ទើបចាប់ទូទាត់តំលៃឈ្នួលប្រចាំខែ បន្តទៅទៀត ។

ប្រការ៣ : ការទទួលខុសត្រូវ :

- ភាគី (ខ) ត្រូវចេញថ្លៃទឹក ភ្លើង ដោយខ្លួនឯង ។

- ថ្លៃទឹក ១ ខែ តំលៃ ១៥.០០០ រ និង ថ្លៃភ្លើង តំលៃ ២៥.០០០រ ។

- ការទូទាត់ថ្លៃឈ្នួលប្រចាំខែ ព្រមទាំងថ្លៃទឹក ភ្លើង ត្រូវមិនឱ្យយឺតយូរ លើសពី មួយសប្តាហ៍ រៀងរាល់ថ្ងៃទី ១ នៃ ខែនីមួយៗ ឡើយ ។

ប្រការ៤: ម្ចាស់ផ្ទះ ភាគី(ក) មិនទទួលខុសត្រូវចំពោះការរកស៊ី ដែលប្រព្រឹត្តផ្ទុយនឹងច្បាប់រដ្ឋនៃភាគី (ខ) ឡើយ ។

ប្រការ៥ : កិច្ចសន្យានេះមានប្រសិទ្ធភាព អនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ, ថ្ងៃទី 01 ខែ សីហា ឆ្នាំ ១៩៩៩

សាក្សីទី ១ សាក្សីទី ២ សាក្សីទី ៣ ភាគី (ខ) ភាគី (ក

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

# កិច្ចសន្យាសាងសង់

ធ្វើនៅ ......................

កាលបរិច្ឆេទ ..........................

កិច្ចសន្យានេះធ្វើឡើងរវាងលោក...................... អាយុ ...... ឆ្នាំ ...... ដែលរស់នៅផ្ទះលេខ .......... ផ្លូវលេខ .......... សង្កាត់ .......... ខណ្ឌ ...............ក្រុង.......... ដែលចាប់ពីថ្ងៃនេះតទៅហៅថា "និយោជក"

និងក្រុមហ៊ុន .......................ដែលមានការិយាល័យចុះបញ្ជីនៅផ្ទះលេខ .......... ផ្លូវលេខ .......... សង្កាត់ .......... ខណ្ឌ ...............ក្រុង.......... ដែលចាប់ពីថ្ងៃនេះតទៅហៅថា "អ្នកម៉ៅការ"

ភាគីទាំងពីរនៃកិច្ចសន្យាព្រមព្រៀងគ្នាតាមល័ក្ខខ័ណ្ឌដូចតទៅ :

១-និយោជកយល់ព្រមជួល ហើយអ្នកម៉ៅការយល់ព្រមឱ្យគេជួល ដើម្បីសាងសង់អាគារមួយដែលមានចំនួន .......... ជាន់នៅលើដីរបស់និយោជកប្លង់ដីលេខ .......... លេខក្រសួងសុរិយោដី .......... សង្កាត់ .......... ខណ្ឌ ............... ក្រុង.......... និងដើម្បីសាងសង់អាគារបែបនេះយោងទៅតាមបង់និងការបញ្ជាក់ដែលភ្ជាប់មកជាមួយកិច្ចសន្យានេះជាគំនូសតាងទី ...........និងទី.......ដែលនឹងចាត់ថាជាផ្នែកមួយនៃកិច្ចសន្យានេះ ។

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

២-អ្នកម៉ៅការយល់ព្រមបញ្ចប់ការសាងសង់យោងតាមខចែងទី ១ ក្នុងរយៈពេល..............ថ្ងៃចាប់ពីថ្ងៃចុះហត្ថលេខានៃកិច្ចសន្យានេះ ។

ក្នុងករណីមានការពន្យាពេលក្នុងការសាងសង់ ដែលបណ្តាលមកពីគ្រោះធម្មជាតិ ឬដោយមិនមែនជាកំហុសរបស់អ្នកម៉ៅការទេនោះ រយៈពេលដែលព្រមព្រៀងគ្នានៅវគ្គខាងលើនឹងត្រូវពន្យាដើម្បីបំពេញចំនួនពេលដែលខាតបង់ ។

៣-ចំពោះកិច្ចការដែលបានចែងនៅក្នុងខចែងទី១ និយោជកយល់ព្រមចេញសងលាភការទៅឱ្យអ្នកម៉ៅការដែលមានទឹកប្រាក់ចំនួន .............. រៀល (......................រៀល) ដែលត្រូវចេញសងជាផ្នែក១ (បណ្តើរ១) តាមសមាមាត្រទៅនឹងការងារដែលបានបញ្ចប់សមស្របទៅនឹងគំរោងពេលចេញសង្ខេបតទៅ :

លើកទី ១ សងបណ្តើរ១ ចំនួន ................ រៀល (...........រៀល)

ក្រោយពីបានបញ្ចប់ ...................... ......................

លើកទី ២ សងបណ្តើរ១ ចំនួន ................ រៀល (...........រៀល)

ក្រោយពីបានបញ្ចប់ ...................... ......................

លើកទី ៣ សងបណ្តើរ១ ចំនួន ................ រៀល (...........រៀល)

ក្រោយពីបានបញ្ចប់ ...................... ......................

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

លើកទី ៤ សងបណ្តើរៗ ចំនួន ................. រៀល (...........រៀល)

ក្រោយពីបានបញ្ចប់ ........................ ........................

ក្នុងហេតុការណ៍ដែលនិយោជកខកខានមិនបានចេញប្រាក់សងបណ្តើរៗណាមួយដូចដែលបានតម្រូវ អ្នកម៉ៅការមានសិទ្ធិនឹងបញ្ចប់កិច្ចសន្យានេះភ្លាម ។ ហើយកាន់កាប់កម្មសិទ្ធិនៃអាគារដោយមិនបាច់បង្វែរជូនវិញនូវលាភការដែលបានចេញសងរួច ។ យោងទៅតាមខចែងនេះ និយោជកត្រូវទូទាត់ជូនអ្នកម៉ៅការនូវការខូចខាតណាមួយ ដែលបណ្តាលមកពីការមិនចេញសងប្រាក់នេះ ។

៤- រាល់សម្ភារៈ បរិក្ខារ និងឧបសាធន (គ្រឿងបន្ទាប់បន្សំ) ទាំងអស់ដែលចាំបាច់សំរាប់ការសាងសង់ នឹងត្រូវនាំមកអោយដោយ ............. ដោយសមស្របទៅតាមបរិមាណនិងគុណភាពដែលបានរៀបរាប់នៅក្នុងគំរោងប្លង់ និងការបញ្ជាក់ដែលជូនភ្ជាប់មកជាមួយកិច្ចសន្យានេះជាគំនូសតាងទី .....និងទី..... ។

៥-ប្រសិនបើនិយោជកចង់ធ្វើការកែទៅលើគំរោងសាងសង់ដោយចំណាយផ្ទាល់ខ្លួននោះ និយោជកត្រូវជូនដំណឹងទៅអ្នកម៉ៅការជាលាយលក្ខអក្សរ ។ អ្នកម៉ៅការរក្សាសិទ្ធិទទួល ឬបដិសេធសំណើរសុំកែគំរោងប្លង់បែបនេះ បន្ទាប់ពីខ្លួនបានគិតអំពីការចាំបាច់ និងការខូចខាតដែលអាចកើតមានឡើងពីការ

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

កែតំរោងប្លង់បែបនេះ ។

៦- អ្នកម៉ៅការយល់ព្រមអនុញ្ញាតអោយនិយោជក ឬភ្នាក់ងាររបស់ខ្លួនដើម្បីត្រួតពិនិត្យការដ្ឋានសាងសង់ ។ យ៉ាងណាក៏ដោយ និយោជកយល់ព្រមថាមិនខាយាំង ឬរំខានដល់ការសាងសងក្នុងវិធីណាមួយឡើយ ។

៧-បើអ្នកម៉ៅការយល់ឃើញថា មិនអាចសាងសង់ហើយនៅក្នុងរយៈពេលដែលបានបញ្ជាក់នៅក្នុងខចែងទី២ទេនោះ អ្នកម៉ៅការ ដោយមានការអនុញ្ញាតជាលាយលក្ខអក្សរពីនិយោជក អាចធ្វើកិច្ចសន្យាបន្តទៅលើផ្នែកណាមួយនៃកិច្ចការអោយទៅអ្នកម៉ៅការបន្តម្នាក់ទៀត ។

៨- និយោជកត្រូវពិនិត្យមើល និងទទួលយកសំណង់ដែលសង់ចប់សព្វគ្រប់ក្នុងរយៈពេល ៧ ថ្ងៃ ចាប់ពីថ្ងៃទទួលការជូនដំណឹងជាលាយលក្ខអក្សរពីអ្នកម៉ៅការ ។ បើសិនជានិយោជក៏មិនអាចធ្វើដូចនេះបាននៅក្នុងរយៈពេលបែបនេះ. នេះនឹងចាត់ទុកថានិយោជកបានត្រួតពិនិត្យមើលនិងបានទទួលយកអាគារ ។

៩- អ្នកម៉ៅការត្រូវទទួលខុសត្រូវនូវរាល់ការខូចខាត ដែលកើតឡើងដោយសារកំហុសនៅក្នុងកិច្ចការសាងសង់របស់ខ្លួននៅក្នុងរយៈពេល ....... ថ្ងៃ ចាប់ពីកាលបរិច្ឆេទដែលនិយោជកទទួលយក ឬចាត់ថាបានទទួលយកអាគារ ដែល

www.budinst.gov.kh www.elibraryofcambodia.org

បានរៀបរាប់នៅក្នុងខចែងទី ៨ ។

១០-ក្នុងករណីយដែលអ្នកម៉ៅការមិនបានប្រគល់កិច្ចការសាងសង់ទាំងស្រុង ហើយដោយមិនមែនជាកំហុសរបស់និយោជកទេនោះ អ្នកម៉ៅការយល់ព្រម អោយនិយោជកពិន័យជាទឹកប្រាក់ចំនួន ............... រៀល (...........រៀល) ក្នុងមួយថ្ងៃ រហូតដល់ការងារសាងសង់ទាំងមូលត្រូវបានទទួលយក ។

កិច្ចសន្យានេះធ្វើជាពីរច្បាប់ ។ ច្បាប់និមួយៗ មានល័ក្ខខ័ណ្ឌនិងឥទ្ធិពលស្មើគ្នា ។ ភាគីទាំងពីរនៃកិច្ចសន្យានេះបានអាននិងយល់សាច់រឿងទាំងស្រុងនៃកិច្ចសន្យាដែលបានចុះហត្ថលេខានិងឈ្មោះនៅពីខាងក្រោមនៅចំពោះវត្តមានសាក្សី ។

| | |
|---|---|
| ហត្ថលេខា.................អ្នកម៉ៅការ | ហត្ថលេខា................. និយោជក |
| ( ) | ( ) |
| ហត្ថលេខា.................សាក្សី | ហត្ថលេខា................. សាក្សី |
| ( ) | ( ) |

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org